# គម្រោងតែងសេចក្តី

# ប្រធានវិញ្ញាសា

# ធ្លាប់ចេញប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ

# ទាំងថ្នាក់វិទ្យាសាស្ត្រពិត

# និងថ្នាក់វិទ្យាសាស្ត្រសង្គម

# ពីឆ្នាំ ២០១៤ - ២០១៩

# មាតិកា

សម័យប្រឡង៖ ០៤ សីហា ២០១៤ .......... 7
សម័យប្រឡង៖ ០៤ សីហា ២០១៤ .......... 11
សម័យប្រឡង៖ ១៣ តុលា ២០១៤ .......... 15
សម័យប្រឡង៖ ១៣ តុលា ២០១៤ .......... 19
សម័យប្រឡង៖ ២៤ សីហា ២០១៥ .......... 22
សម័យប្រឡង៖ ២៤ តុលា ២០១៥ .......... 26
សម័យប្រឡង៖ ២២ សីហា ២០១៦ .......... 29
សម័យប្រឡង៖ ២២ សីហា ២០១៦ .......... 33
សម័យប្រឡង៖ ២១ សីហា ២០១៧ .......... 37
សម័យប្រឡង៖ ២១ សីហា ២០១៧ .......... 42
សម័យប្រឡង៖ ២០ សីហា ២០១៨ .......... 46
សម័យប្រឡង៖ ២០ សីហា ២០១៨ .......... 50
សម័យប្រឡង៖ ១៩ សីហា ២០១៩ .......... 54
សម័យប្រឡង៖ ១៩ សីហា ២០១៩ .......... 57
ឯកសារយោង .......... 61

# ប្រធានវិញ្ញាសាធ្លាប់ចេញប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ទាំងថ្នាក់វិទ្យាសាស្ត្រពិត និងថ្នាក់វិទ្យាសាស្ត្រសង្គម ពីឆ្នាំ ២០១៤ - ២០១៩

## សម័យប្រឡង៖ 0៤ សីហា ២០១៤

## វិញ្ញាសា៖ អក្សរសាស្ត្រខ្មែរ ( ថ្នាក់វិទ្យាសាស្ត្រ )

ប្រធានមានទស្សនៈមួយបែងថា «អក្សរសិល្ប៍គឺជាកញ្ចក់សម្រាប់ឆ្លុះសង្គម»។ ចូរធ្វើការបកស្រាយទស្សនៈនេះ ដោយរកឧទាហរណ៍ក្នុងអក្សរសិល្ប៍មកបញ្ជាក់។

## សម័យប្រឡង៖ 0៤ សីហា ២០១៤

## វិញ្ញាសា៖ អក្សរសាស្ត្រខ្មែរ ( ថ្នាក់វិទ្យាសាស្ត្រសង្គម )

ប្រធាន ពាក្យចាស់លោកថា « ឱ្យតែខំច្រើនកើនចំណេះ តែបេះការច្រើនជាបច្ច័យ តែខំរៀនសូត្ររៀងរាល់ថ្ងៃ ដូចថ្នៃត្បូងពេជ្រលេចពន្លឺ»។ចូរបកស្រាយដោយរកអំណះអំណាងក្នុងអក្សរសិល្ប៍មកបញ្ជាក់។

## សម័យប្រឡង៖ ១៣ តុលា ២០១៤

## វិញ្ញាសា៖ អក្សរសាស្ត្រខ្មែរ ( ថ្នាក់វិទ្យាសាស្ត្រ )

ប្រធាន មានទស្សនៈមួយបែងថា«អក្សរសាស្ត្ររលត់ជាតិរលាយ អក្សរសាស្ត្រពណ្ណរាយជាតិថ្កើងថ្កាន»។ ចូរបកស្រាយទស្សនៈនេះដោយយកការវិវត្តនៃចលនាអក្សរសិល្ប៍មកបញ្ជាក់។

## សម័យប្រឡង៖ ១៣ តុលា ២០១៤

## វិញ្ញាសា៖ អក្សរសាស្ត្រខ្មែរ ( ថ្នាក់វិទ្យាសាស្ត្រសង្គម )

ប្រធាន មានសុភាសិតខ្មែរមួយបែងថា៖ «តក់ៗ ពេញបំពង់» ។ចូរបកស្រាយសុភាសិតនេះដោយរកអំណះអំណាងក្នុងអក្សរសិល្ប៍មកបញ្ជាក់។

## សម័យប្រឡង៖ ២៤ សីហា ២០១៥

## វិញ្ញាសា៖ អក្សរសាស្ត្រខ្មែរ ( ថ្នាក់វិទ្យាសាស្ត្រ )

ប្រធាន សុភាសិតមួយបានចែងថា «ការងារជាមាសប្រាក់» ។ ចូរបកស្រាយដោយរកអំណះអំណាងនៅក្នុងអក្សរសិល្ប៍មកបញ្ជាក់។

## សម័យប្រឡង៖ ២៤ តុលា ២០១៥

## វិញ្ញាសា៖ អក្សរសាស្ត្រខ្មែរ ( ថ្នាក់វិទ្យាសាស្ត្រសង្គម )

ប្រធាន មានទស្សនៈមួយចែងថា«ការតស៊ូគឺជាគន្លឹះដើម្បីទទួលបានសុភមង្គល»។ ចូរបកស្រាយទស្សនៈនេះដោយយកឧទាហរណ៍ក្នុងអក្សរសិល្ប៍មកបញ្ជាក់។

## សម័យប្រឡង៖ ២២ សីហា ២០១៦

## វិញ្ញាសា៖ អក្សរសាស្ត្រខ្មែរ ( ថ្នាក់វិទ្យាសាស្ត្រ )

ប្រធាន មានមតិមួយពោលថា« អត្ថបទអក្សរសិល្ប៍មានគោលដៅអប់រំមនុស្សឱ្យចេះដោះស្រាយបញ្ហា »។ ចូរបកស្រាយដោយរកឧទាហរណ៍នៅក្នុងអក្សរសិល្ប៍មកបញ្ជាក់។

## សម័យប្រឡង៖ ២២ សីហា ២០១៦

## វិញ្ញាសា៖ អក្សរសាស្ត្រខ្មែរ ( ថ្នាក់វិទ្យាសាស្ត្រសង្គម )

ប្រធាន មានទស្សនៈមួយពោលថា« ការអប់រំគឺជាសិទ្ធិសេរីភាពដែលបើកផ្លូវឱ្យមនុស្សសម្រេចបានភាពថ្លៃថ្នូរក្នុងជីវិត »។ ចូរបកស្រាយទស្សនៈនេះដោយរកឧទាហរណ៍ក្នុងអក្សរសិល្ប៍មកបញ្ជាក់។

## សម័យប្រឡង៖ ២១ សីហា ២០១៧

## វិញ្ញាសា៖ អក្សរសាស្ត្រខ្មែរ ( ថ្នាក់វិទ្យាសាស្ត្រ )

ប្រធាន មានទស្សនៈមួយចែងថា« ការសិក្សាពេញមួយជីវិតគឺជារបៀបនៃការអប់រំក្នុងសតវត្សទី ២១ »។ ចូរអធិប្បាយពន្យល់ទស្សនៈខាងលើនេះដោយលើកឧទាហរណ៍មកបញ្ជាក់។

## សម័យប្រឡងៈ ២១ សីហា ២០១៧

## វិញ្ញាសាៈ អក្សរសាស្ត្រខ្មែរ ( ថ្នាក់វិទ្យាសាស្ត្រសង្គម )

ប្រធាន ក្នុងច្បាប់ល្បើកថ្មី អ្នកកវីកម្សាភាសាអ៊ូហៅង៉ុយបានពោលថា« បម្រើមើលពុត ប្រាជ្ញាឱ្យមុត ស្មារតីឱ្យមាន បើខ្លាចឱ្យប្រាជ្ញ បើខ្លាចឱ្យហ៊ាន ចង់បានរបៀន កុំអៀនកុំខ្មាស »។ ចូរបកស្រាយដោយរកឧទាហរណ៍ក្នុងអក្សរសិល្ប៍មកបញ្ជាក់។

## សម័យប្រឡងៈ ២០ សីហា ២០១៨

## វិញ្ញាសាៈ អក្សរសាស្ត្រខ្មែរ ( ថ្នាក់វិទ្យាសាស្ត្រសង្គម )

ប្រធាន មានទស្សនៈមួយបែងថា« វិជ្ជាជាអលង្ការរបស់មនុស្សគ្រប់រូប »។ ចូរអ្នកធ្វើការបកស្រាយ ដោយលើកឧទាហរណ៍ក្នុងអក្សរសិល្ប៍ខ្មែរមកបញ្ជាក់។

## សម័យប្រឡងៈ ២០ សីហា ២០១៨

## វិញ្ញាសាៈ អក្សរសាស្ត្រខ្មែរ ( ថ្នាក់វិទ្យាសាស្ត្រពិត )

ប្រធាន មានទស្សនៈមួយបែងថា« សេចក្តីព្យាយាមគង់បានសម្រេច »។ ចូរបកស្រាយដោយរកអំណះអំណាងក្នុងអក្សរសិល្ប៍មកបញ្ជាក់។

## សម័យប្រឡងៈ ១៩ សីហា ២០១៩

## វិញ្ញាសាៈ អក្សរសាស្ត្រខ្មែរ ( ថ្នាក់វិទ្យាសាស្ត្រពិត )

ប្រធាន « អក្សរសិល្ប៍ឆ្លុះបញ្ចាំងពីការប្រយុទ្ធរវាងភាវៈល្អ និងភាវៈអាក្រក់ »។ ចូរអ្នកបកស្រាយដោយយកអត្ថបទអក្សរសិល្ប៍មកបញ្ជាក់។

## សម័យប្រឡងៈ ១៩ សីហា ២០១៩

## វិញ្ញាសាៈ អក្សរសាស្ត្រខ្មែរ (ថ្នាក់វិទ្យាសាស្ត្រសង្គម)

ប្រធាន « អក្សរសិល្ប៍ខេមរនិយមបង្ហាញពីសង្គមខ្មែរតាមសម័យកាលនីមួយៗ »។ ចូរអ្នកធ្វើការបកស្រាយដោយយកអត្ថបទអក្សរសិល្ប៍ចំនួនបីមកបញ្ជាក់។

# ប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ( ប្រឡងលើកទី១ )

## សម័យប្រឡង៖ ០៤ សីហា ២០១៤

## វិញ្ញាសា៖ អក្សរសាស្ត្រខ្មែរ ( ថ្នាក់វិទ្យាសាស្ត្រ )

## រយៈពេល៖ ៩០នាទី ពិន្ទុ ៧៥

ប្រធាន៖ មានទស្សនៈមួយថែងថា «អក្សរសិល្ប៍គឺជាកញ្ចក់សម្រាប់ឆ្លុះសង្គម» ។ ចូរធ្វើការបកស្រាយទស្សនៈនេះ ដោយរកឧទាហរណ៍ក្នុងអក្សរសិល្ប៍មកបញ្ជាក់ ។

### គម្រោងតែង

### ១.ផ្ដើមសេចក្ដី

- លំនាំសេចក្ដី
- ចំណូលសេចក្ដី
- ចំណោទសេចក្ដី

### ២.តួសេចក្ដី

- ឃ្លាភ្ជាប់សេចក្ដី
- ពន្យល់ពាក្យ
  - **អក្សរសិល្ប៍៖** គឺជាកម្រងអត្ថបទដែលបានប្រមូលចងក្រងនូវរឿងរ៉ាវ ឬហេតុការណ៍ដែលបានកើតឡើងនៅក្នុងសង្គមប្រកបដោយសិល្បៈវិធី។
  - **កញ្ចក់សម្រាប់ឆ្លុះបញ្ចាំង៖** ការធ្វើឱ្យឃើញពីអ្វី។

- **ពន្យល់ន័យប្រធាន៖**មតិប្រធានចង់បង្ហាញឱ្យយើងបានដឹងថាតម្លៃនៃអត្ថបទទាំងឡាយដែលបានលើកយកមកបង្ហាញឱ្យឃើញពីអ្វីៗដែលបានកើតឡើងនៅក្នុងសង្គមនៃការរស់នៅរបស់មនុស្ស។
- **បកស្រាយប្រធាន**

**បកស្រាយ៖** «អក្សរសិល្ប៍ជាកញ្ចក់ឆ្លុះបញ្ចាំងសង្គម» ដូចបានបង្ហាញឱ្យឃើញពី៖

- របបគ្រប់គ្រងសង្គមតាមសម័យកាលនីមួយៗ (បង្ហាញឱ្យឃើញពីតថភាពសង្គម)
- ជីវភាពរស់នៅរបស់ប្រជាជនក្នុងសង្គម.......
- ជំនឿសាសនា  ទំនៀមទម្លាប់ប្រពៃណី ក្នុងការរស់នៅ....
- ទង្វើអយុត្តិធម៌ដែលកើតមានក្នុងសង្គម...
- សកម្មភាពនៃការតស៊ូប្រឆាំងនឹងខ្មាំងសត្រូវ ដើម្បីទាមទារកម្មសិទ្ធ សេរីភាព និងឯករាជជាតិ។
- សកម្មភាពបុព្វបុរសក្នុងការចូលរួមកសាង ការពារ និងអភិវឌ្ឍសង្គមឱ្យមានការរីកចម្រើន។

លើឧទាហរណ៍បញ្ជាក់ក្នុងអក្សរសិល្ប៍(២០ពិន្ទុ)

អក្សរសិល្ប៍ប្រជាប្រិយ

- **រឿងធនញ្ជ័យ៖** បង្ហាញពីរបបរាជានិយមខ្មែរ ដែលទទួលរងការរាទីពីបរទេស(ចិន) និងការតស៊ូរបស់បុព្វបុរសខ្មែរក្នុងការការពារទឹកដីឱ្យបានគង់វង្ស។
- **អ្នកតាទឹកអ្នកតាភ្នំ ៖** បានបង្ហាញពីសកម្មភាពរបស់បណ្តាប្រជាជនមួយចំនួនធំដែលមានគំនិតធ្វើ ការតស៊ូប្រឆាំងនឹងធម្មជាតិ ក្នុងបំណងធ្វើជាម្ចាស់លើធម្មជាតិ។ (អ្នកតាភ្នំជាតំណាង)

អក្សរសិល្ប៍បុរាណ

- **រឿងរាមកេរ្តិ៍៖** បានបង្ហាញពីទំនាស់ក្នុងការបែងចែករាជសម្បត្តិ ការគោរពពាក្យសច្ចៈ(ពាក្យ សត្យ) និងប្រពៃណីព្រះមហាក្សត្រ...។

- **រឿងទុំទាវ៖** បានបង្ហាញឱ្យឃើញពីតថភាពសម័យលង្វែក ដែលតែងនិយមប្រើអំណាចផ្ដាច់ការតាំងពីក្នុងសង្គមទាំងមូល។

  - *សង្គមគ្រួសារ* ៖ មានមេគ្រួសារអនុវត្តទំនៀមទម្លាប់ចាស់គំរិល បំបិទសិទ្ធសេរីភាពក្នុងការជ្រើសរើសគូស្រករដល់បុត្ររបស់ខ្លួន «នំមិនធំជាងនាឡិ»។
  - *សង្គមទាំងមូល៖* អ្នកដែលមានអំណាចទ្រព្យសម្បត្តិនិងអំណាចយសសក្តិរមែងតែងប្រើអំណាច របស់ខ្លួនក្នុងការគាបសង្កត់វាយធ្វើបានអ្នកទន់ខ្សោយ ដោយមិនទទួលទោសពៃរ៍អ្វីឡើយ ដូចមានអរជូនជាដើម។ «ឧកញ៉ាអរជូនមួនមាំពេក...កាប់ចាក់វាយដំពុំប្រណី»។

- **រឿងព្រះវេស្សន្តរ៖** បានបង្ហាញឱ្យឃើញពីរបបគ្រប់គ្រងរបស់ព្រះបាទស្រីសញ្ជ័យ ដែលបានប្រកាន់របបគ្រប់គ្រងបែបលទ្ធិប្រជាធិបតេយ្យ យកមតិរបស់ប្រជានុរាស្ត្រជាធំ (បណ្ដេញព្រះវេស្សន្តរតាមសម្តីរបស់បណ្ដារាស្ត្រ)។

- .........................។

អក្សរសិល្ប៍ទំនើប

- **រឿងភូមិតិរច្ឆាន៖** បានបង្ហាញពីទុក្ខដ៏សែនវេទនារបស់ប្រជាជនខ្មែរ ដែលត្រូវបានរស់នៅក្រោម ការត្រួតត្រា និងការប្រើអំណាចផ្ដាច់ការរបស់ពួកអាណានិគមបារាំងតាមរូបភាព៖

  - បារាំងបានបង្ខំខ្មែរឱ្យធ្វើការបង់ពន្ធគ្រប់មុខសព្វសារពើ....
  - ក្រោយព្រឹត្តិការណ៍១៨ មេសា ១៩២៥...

- បង្ហាញពីសកម្មភាពតស៊ូរបស់ប្រជាជនខ្មែរប្រឆាំង ដើម្បីបុព្វហេតុជាតិ។

- រឿងគូលីកំណែនេះ អ្នកនិពន្ធបានបង្ហាញពីតថភាពពិតរបស់ប្រជាជនខ្មែរដែលរងការឈឺចាប់ដោយសារការគាបសង្កត់របស់ពួកសក្តិភូមិអាណានិគមបារាំង ផាស៊ីសជប៉ុន និងចក្រពត្តិអាមេរិក។

**សរុបមតិ( ៥ពិន្ទុ )**

រួមសេចក្តីមកស្របទៅតាមការអត្ថាធិប្បាយ និងដូចឧទាហរណ៍ដែលបានបញ្ជាក់យ៉ាងច្បាស់ទៅតាមរឿងនីមួយៗ ខាងលើយើងអាចដឹងបានថាអក្សរសិល្ប៍ពិតជាកញ្ចក់សម្រាប់ឆ្លុះបញ្ចាំងតថភាពសង្គមខ្មែរប្រាកដមែន។

## ៣.បញ្ចប់សេចក្តី

- **វាយតម្លៃប្រធាន៖** ជាបញ្ចប់មកយើងអាចសន្និដ្ឋានបានថាមតិរបស់ប្រធានពិតជាមានតម្លៃនិងអត្ថន័យដ៏ល្អជ្រាលជ្រៅ សម្រាប់បង្ហាញពីមុខងារនឹងតម្លៃគ្រប់រឿងអក្សរសិល្ប៍ខ្មែរទាំងអស់ដែលនិពន្ធបានតាក់តែងមក។
- **ទស្សនៈផ្ទាល់ខ្លួន៖** ដូចនេះ..........................................។

## រចនាបថ

**កំណត់ចំណាំ៖** *កិច្ចការសិស្សដែលបានលើករឿងអក្សរសិល្ប៍ផ្សេងៗដែលសមស្របក្រៅពីអត្រាកំណែត្រូវបានពិន្ទុដូចក្នុងអត្រាកំណែ។ (ឧទាហរណ៍រឿងក្នុងអក្សរសិល្ប៍យ៉ាងតិចពីររឿង ទើបបានពិន្ទុពេញ)។*

# ប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ( ប្រឡងលើកទី១ )

## សម័យប្រឡង៖ ០៤ សីហា ២០១៤

## វិញ្ញាសា៖ អក្សរសាស្ត្រខ្មែរ ( ថ្នាក់វិទ្យាសាស្ត្រសង្គម )

## រយៈពេល៖ ១៥០នាទី ពិន្ទុ ១២៥

ប្រធាន ពាក្យចាស់លោកថា « ឱ្យតែខំច្រើនកើនចំណេះ តែចេះការច្រើនជាបច្ច័យតែខំរៀនសូត្ររៀងរាល់ថ្ងៃ ដូចថ្មៃត្បូងពេជ្រលេចពន្លឺ »។ ចូរបកស្រាយដោយរកអំណះអំណាងក្នុងអក្សរសិល្ប៍មកបញ្ជាក់។

## អត្ថាធិប្បាយកំណែ

### ១.ផ្ដើមសេចក្ដី

- **លំនាំសេចក្ដី**
- **ចំណូលសេចក្ដី**
- **ចំណោទសេចក្ដី**

### ២.តួសេចក្ដី

- **ឃ្លាភ្ជាប់សេចក្ដី**
- **ពន្យល់ពាក្យ**
    - **កើនចំណេះ៖** គឺរីកចម្រើនទន្ទឹមចំណេះជំនាញ ការដឹងគ្រប់សារពើ....
    - **បច្ច័យ៖** គឺជាហេតុ ជាដើមចម...
    - **ថ្មៃ៖** គឺការកែលម្អ និងធ្វើអ្វីមួយដែលគ្មានសោភ័ណ គ្មានតម្លៃ គ្មានប្រយោជន៍ ទៅជាមានតម្លៃ មានប្រយោជន៍ មានសោភ័ណជាងមុន។
- **ពន្យល់ន័យប្រធាន៖**មតិប្រធានមានន័យថា តែខំច្រើននឹងនាំឱ្យមានការរីកចម្រើនទន្ទឹមចំណេះដឹង ចំណេះជំនាញ សព្វសារពើ តែចេះការងារច្រើនជាហេតុ

ផលជាដើមចម តែខំរៀនសូត្ររាល់ថ្ងៃខែប្រៀបដូចការកែលម្អនៃត្បូងពេជ្រឱ្យលេចចេញជាពន្លឺ។

- **បកស្រាយប្រធាន**

## ក.បកស្រាយគំនិតទូទៅ

ដោយឆ្លងកាត់បទពិសោធន៍ក្នុងជីវិតរស់នៅ ក្នុងការងារ ក្នុងធម្មជាតិ ទើបចាស់បុរាណបានខិតខំចងក្រងជាក្បួនច្បាប់ផ្សេងៗ ដើម្បីទុកជាគតិអប់រំទូន្មានប្រៀនប្រដៅដល់អនុជនជំនាន់ក្រោយឱ្យមានការយល់ដឹង ពីវិធីនៃការបង្កើនចំណេះដឹងទូទៅ ពីហេតុផលផ្សេងៗ និងពីតម្លៃនៃការសិក្សារៀនសូត្រ។...

## ខ.គំនិតបំភ្លឺប្រធាន

ដូចបានបង្ហាញខាងលើរួចមកហើយ

- **តែខំប្រើនកើនចំណេះ** ៖មានន័យថា កាលណាបុគ្គលគ្រប់រូបខិតខំប្រឹងប្រែងពុះពារឧបសគ្គ ជំនះនូវ បញ្ហានានា គេតែងទទួលបានមកវិញនូវចំណេះដឹងទូទៅនិងបទពិសោធន៍ជាច្រើន...។
    - **រឿងកុលាបប៉ៃលិន៖** ចៅចិត្រខិតខំបំពេញការងារជាកម្មករត្បូងនាំឱ្យចេះស្ទាត់ជំនាញលើកិច្ចការជីកត្បូងរហូតក្លាយជាអ្នកគ្រប់គ្រងអណ្តូងរ៉ែត្បូង...
    - **រឿងព្រះអាទិត្យថ្មីរះលើផែនដីចាស់៖** ការព្យាយាមរបស់តួអង្គសមក្នុងមុខរបរកសិកម្ម នាំឱ្យសមក្លាយជាកសិករគំរូ។
    - **រឿងមាយើង៖** ដោយក្តីព្យាយាមអនុវត្តតាមការណែនាំរបស់ប្រពន្ធទើបនាំឱ្យចៅមាណបានក្លាយជាមន្ត្រីជំនិតរបស់ព្រះរាជា។
    - **រឿងកុមារកំព្រា៖** ការព្យាយាមរបស់កុមារប្អូនៗក្នុងការធ្វើផុចដាក់ត្រី នាំឱ្យជំនាញក្នុងការធ្វើផុចរបស់កុមារមានការរីវឌ្ឍពីផុចដាក់ម្រឹគរហូតដាក់យក្សជាប់។*(ស្មេរអាចលើកឧទាហរណ៍ក្នុងស្នាដៃផ្សេងៗទៀត)*

- **តែបេះការច្រើនជាបច្ច័យ៖** មានន័យថា ការដែលបុគ្គលយល់ដឹងពីរបៀបធ្វើការងារច្រើននាំឱ្យបុគ្គលក្លាយជាអ្នកដែលមានហេតុផលល្អ មានការយល់ដឹងពីតម្លៃនៃការងារ មិនប្រមាទការងារបេះទាញប្រយោជន៍ពីការងារ...។
  - **រឿងកុលាបប៉ៃលិន៖** ដោយសារការបេះ ការយល់ដឹងពីការងារច្រើន (ដីកត្បូង បើកទូ្បាន ការងារប្រចាំថ្ងៃ) ទើបធ្វើឱ្យមានការចាប់អារម្មពីហ្លួងរតន:សម្បត្តិ និងនាងឃុននារី។
  - **រឿងព្រះអាទិត្យថ្មីរះលើផែនដីចាស់៖** សមមានការយល់ដឹងពីជីវិតជាកម្មករ និងជាកសិករ ទើបគាត់ហ៊ានបដិសេធលុយ៥០០៛របស់លោករដ្ឋមន្ត្រីវ័យក្មេង និងត្រូវបានប្រជានុរាស្ត្របោះឆ្នោតជ្រើសតាំងជាគណកម្មការឃុំក្នុងសម័យសង្គមរាស្ត្រនិយម ។
  - **រឿងតេជោយ៉ត៖** ដោយសារតែមានការយល់ដឹងច្រើនពីក្បួនតម្រាពិជ័យសង្គ្រាម ទើបតេជោយ៉តអាចដឹកនាំទ័ពបង្រ្កាបឈ្លើយសឹកសៀមបានជោគជ័យ ពិសេសអាចធ្វើឱ្យគាត់រកឃើញសត្រូវក្រោយខ្នងទៀតផង ។
- **តែខំរៀនសូត្ររាល់ថ្ងៃខែដូចច្នៃត្បូងពេជ្រលេចពន្លឺ៖** មានន័យថា បើកាលណាបុគ្គលគ្រប់រូបខិតខំព្យាយាមរៀនសូត្រជាប្រចាំបុគ្គលនោះនឹងមានចំណេះដឹងជ្រៅជ្រះ មានកេរ្តិ៍ឈ្មោះល្បីសុះសាយដូចជាត្បូងពេជ្រដែលពីមុនគ្រាន់តែជាដុំក្រួស ជាវ៉ែធម្មតា លុះក្រោយពេលធ្វើកំណែច្នៃរួចមក វាក៏ក្លាយជាត្បូងដែលមានពន្លឺ មានសោភ័ណ មានតម្លៃគួរជាទីពេញនិយមពីអ្នកដទៃ។
  - **រឿងរាមកេរ្តិ៍៖** ព្រះរាមមានកេរ្តិ៍ឈ្មោះល្បីល្បាញដោយសារព្រះអង្គមានថ្វីដៃក្នុងការលើកធ្នូនិងបង្ក្រាបសត្រូវ។ ព្រះអង្គទទួលបានចំណេះដឹងនេះដោយសារទ្រង់បានសិក្សាបេះចប់គម្ពីរវេទជាមួយឥសីព្រិស្វាមិត្រ។

- **រឿងព្រះអាទិត្យថ្មីរះលើផែនដីចាស់៖** សម្តេចព្រះនរោត្តមសីហនុ បិតាឯករាជ្យជាតិ ព្រះអង្គមានការសិក្សាខ្ពស់ទាំងខាងវិទ្យាសាស្ត្រ សង្គម បច្ចេកទេស ការគ្រប់គ្រងបានធ្វើឱ្យព្រះកិត្តិនាមព្រះអង្គល្បីល្បាញពេញពិភពលោក ។

- **សរុបសេចក្តីមក** ដោយមានហេតុផលដូចបានបកស្រាយខាងលើឃើញថា បើបុគ្គលខំប្រឹងនាំឱ្យរីកចម្រើនផ្នែកចំណេះ តែចេះការងារច្រើនជាលំនាំឱ្យស្គាល់ហេតុផល តែបើខិតខំរៀនសូត្រជាប្រចាំនាំឱ្យមានភាពល្បីល្បាញ។

## ៣.បញ្ចប់សេចក្តី

- **វាយតម្លៃប្រធាន៖** ប្រធានពិតជាមានអត្ថន័យល្អក្នុងការអប់រំមនុស្សទូទៅឱ្យស្គាល់ពីតម្លៃនៃការខិតខំព្យាយាមរៀនសូត្រ និងបំពេញការងារផ្សេងៗដើម្បីប្រយោជន៍និងកេរ្តិ៍ឈ្មោះ...។
- **ទស្សនៈផ្ទាល់ខ្លួន៖** ដូចនេះបុគ្គលទាំងឡាយគួរតែខិតខំព្យាយាមរៀនសូត្រនូវចំណេះដឹង និងចំណេះធ្វើដែលល្អប្រសើរ...។

របនាបថ

# ប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ(ប្រឡងលើកទី២)

## សម័យប្រឡង៖ ១៣ តុលា ២០១៤

## វិញ្ញាសា៖ អក្សរសាស្ត្រខ្មែរ (ថ្នាក់វិទ្យាសាស្ត្រ)

## រយៈពេល៖ ៩០នាទី ពិន្ទុ ៧៥

ប្រធាន មានទស្សនៈមួយថែងថា«អក្សរសាស្ត្ររលត់ជាតិរលាយ អក្សរសាស្ត្រពណ្ណរាយជាតិថ្កើងថ្កាន»។ ចូរបកស្រាយទស្សនៈនេះ ដោយយកការវិវត្តនៃចលនាអក្សរសិល្ប៍មកបញ្ជាក់។

## អត្រាកំណែ

### ១.ផ្តើមសេចក្តី

- លំនាំសេចក្តី
- ចំណូលសេចក្តី
- ចំណោទសេចក្តី

### ២.តួសេចក្តី

- ឃ្លាភ្ជាប់សេចក្តី
- ពន្យល់ពាក្យ
    - *អក្សរសាស្ត្រ៖* ក្បួនច្បាប់អក្សរ គម្ពីរភាសា មូលដ្ឋានគ្រឹះនៃភាសាជាតិ ...។
    - *រលត់រលាយ៖* បាត់បង់ សាបសូន្យ...។
    - *ពណ្ណរាយ៖* ពន្លឺរស្មីត្រចះត្រចង់...។
    - *ថ្កើងថ្កាន៖* រុងរឿង រីកចម្រើន...។
- ពន្យល់ន័យប្រធាន៖

មតិប្រធានចង់បង្ហាញឱ្យយើងបានដឹងថាក្បួនច្បាប់ទាំងឡាយនៅពេលវាបាត់បង់សាបសូន្យ គឺនឹងនាំឱ្យជាតិចុះអន់ថយទៅតាមនោះដែរ តែបើក្បួនច្បាប់ទាំងនោះនៅឋិតថេរនឹងរីកចម្រើន សង្គមជាតិក៏រីកចម្រើនទៅតាមនោះដែរ ។

- **បកស្រាយប្រធាន៖**

ក. បង្ហាញពីតម្លៃអក្សរសាស្ត្រខ្មែរ

- ជាមូលដ្ឋានគ្រឹះសម្រាប់ទ្រទ្រង់ប្រទេសជាតិ
- ជាដួងព្រលឹងនៃប្រទេសជាតិ
- ជាអត្តសញ្ញាណជាតិខ្មែរ
- ជាមធ្យោបាយសម្រាប់ទំនាក់ទំនងគ្រប់ប្រភេទ
- ផ្តល់នូវពុទ្ធិ ចំណេះដឹង និងការអប់រំដ៏ច្រើនសម្រាប់កូនចៅជាតិខ្មែរ។

ខ.កាលណាអក្សរសាស្ត្ររលត់ពិតជានាំឱ្យជាតិត្រូវរលាយ

- អត្តសញ្ញាណជាតិ
- ពូជសាសន៍ត្រូវគេមើលងាយ
- បាត់បង់វប្បធម៌ ទំនៀមទម្លាប់...
- ប្រទេសជាតិត្រូវធ្លាក់ចុះ អន់ថយ...
- ត្រូវរស់នៅក្រោមចំណុះប្រទេសដទៃ...

ឧទាហរណ៍ ៖ វិវត្តចលនាអក្សរសិល្ប៍

សម័យអាណានិគមបារាំង

- បារាំងបានបំបាត់អក្សរសាស្ត្រខ្មែរ បំបាត់វប្បធម៌ខ្មែរ ហើយបំពាក់បំពុលវប្បធម៌របស់បារាំង។ អក្សរសាស្ត្រខ្មែររត់ទៅសម្ងំនៅក្នុងវត្តអារាមដើម្បីឱ្យព្រះសង្ឃជួយថែរក្សា ពេលនោះជាតិខ្មែរមានការធ្លាក់ចុះដុនដាបស្ថិតនៅក្រោមចំណុះបារាំង។
- **រឿងភូមិតិរច្ឆាន៖** បានបង្ហាញពីទុក្ខសោករបស់ប្រជារាស្ត្រខ្មែរ ដោយរស់នៅក្រោមការគាបសង្កត់ និងប្រើអំណាច ផ្តាច់ការរបស់ពួកបារាំង

សម័យប៉ុលពត

- អក្សរសាស្ត្រត្រូវបាត់បង់ទាំងស្រុង ពេលនោះប្រទេសខ្មែរក្លាយជាវាល ពិឃាត។

គ.កាលណាអក្សរសាស្ត្រពណ្ណរាយនោះនឹងនាំឱ្យប្រទេសជាតិមានការរីក ចម្រើនគ្រប់វិស័យ

- ប្រទេសជាតិទទួលបានឯករាជ្យ
- មានកិត្យានុភាព សមភាព តម្លាភាព
- ជាតិ ពូជសាសន៍ ស្ថិតស្ថេរ គង់វង្ស
- មានបូរណភាពទឹកដី
- បរទេសមិនមើងាយ មិនហ៊ានឈ្លានពាន...។

វិវត្តចលនាអក្សរសិល្ប៍សម័យអង្គរ

អក្សរសាស្ត្រខ្មែរ មានភាពរុងរឿងមានអ្នកនិពន្ធល្បីៗ ជាច្រើន ពេលនោះប្រទេស ជាតិមានភាពល្បីល្បាញរុងរឿង។

- **រឿងរាមកេរ្តិ៍៖** បានបញ្ជាក់ពីសកម្មភាពរបស់ព្រះបាទទសរថ ដែលជា ក្សត្រមួយព្រះអង្គដែលប្រកាន់ពាក្យសត្យ និងប្រវេណីក្សត្រត្រឹមត្រូវ ដែលអាចញ៉ាំងឱ្យព្រះនគរ គេចផុតពីសង្គ្រាម បណ្តារាស្ត្ររស់នៅ ប្រកបដោយសេចក្តីសុខ សុភមង្គល។

អក្សរសិល្ប៍សម័យឯករាជ្យ៖ អក្សរសិល្ប៍ក្នុងសម័យនេះមានការរីកចម្រើនខ្លាំង ហើយប្រទេសជាតិក៏បានប្រែមុខមាត់ថ្មីស្គាលឥស្សរភាពខ្មែរពិតប្រាកដ។

- **រឿងព្រះអាទិត្យថ្មីរះលើផែនដីចាស់៖** អ្នកនិពន្ធបានបញ្ជាក់ពីភាពរីក ចម្រើនជឿនទលឿន ក្នុងសម័យសង្គមរាស្ត្រនិយម ហើយពេលនេះ អក្សរសាស្ត្រជាតិក៏មានភាពរុងរឿងផងដែរ ។

អក្សរសិល្ប៍សម័យបច្ចុប្បន្ន ក្នុងសម័យនេះមានការរីកចម្រើនខ្លាំងហើយប្រទេស មានការលូតលាស់...។

*(ចំណាំ៖ បើសិស្សលើកយករឿងដែលស្ថិតក្នុងចលនាអក្សរសិល្ប៍ទាំងបួន រឿងណាក៏បានឱ្យតែស្របនឹងប្រធានក៏ត្រូវបានពិន្ទុដែរ។)*

- **សរុបសេចក្ដី** រួមសេចក្ដីមក បើអក្សរសាស្ត្ររលត់នោះប្រទេសជាតិនឹងត្រូវបាត់បង់អត្តសញ្ញាណខ្លួន តែបើប្រទេសជាតិមានអក្សរសាស្ត្ររីកចម្រើននោះប្រទេសជាតិក៏មានការអភិវឌ្ឍរុងរឿងដែរ។

## ៣.បញ្ចប់សេចក្ដី

- **វាយតម្លៃប្រធាន៖** ជាបញ្ចប់មកយើងអាចសន្និដ្ឋានបានថាមតិរបស់ប្រធានពិតជាមានតម្លៃ និងអត្ថន័យដ៏ល្អជ្រាលជ្រៅសម្រាប់បង្ហាញឱ្យឃើញពីតម្លៃនៃអក្សរសាស្ត្រជាតិ ដែលដើរតួយ៉ាងសំខាន់សម្រាប់អភិវឌ្ឍប្រទេសជាតិ ក៏ដូចជាធ្វើឱ្យធ្លាក់ចុះដុនដាបដែរ។
- **ទស្សនៈផ្ទាល់ខ្លួន៖** ដូចនេះ ...ត្រូវស្រឡាញ់ ត្រូវអភិរក្សាអក្សរសាស្ត្រជាតិ

របនាបថ៖

# ប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ (ប្រឡងលើកទី២)

## សម័យប្រឡង៖ ១៣ តុលា ២០១៤

## វិញ្ញាសា៖ អក្សរសាស្ត្រខ្មែរ (ថ្នាក់វិទ្យាសាស្ត្រសង្គម)

## រយៈពេល៖ ១៥០នាទី ពិន្ទុ ១២៥

ប្រធាន មានសុភាសិតខ្មែរមួយចែងថា៖ «តក់ៗ ពេញបំពង់» ។ ចូរបកស្រាយសុភាសិតនេះដោយរកអំណះអំណាងក្នុងអក្សរសិល្ប៍មកបញ្ជាក់ ។

## អត្ថាកំណែ

- **លំនាំសេចក្តី៖** លើកយកបញ្ហាទូទៅទាក់ទងនឹងប្រធាន
- **ចំណូលសេចក្តី៖** បញ្ចូលគំនិតប្រធាន
- **ចំណោទសេចក្តី៖** តើសុភាសិតខាងលើមានអត្ថន័យដូចម្តេចខ្លះ?

## ២.តួសេចក្តី

- **ឃ្លាភ្ជាប់សេចក្តី**
- **ពន្យល់ពាក្យ**
  - តក់ៗ មានន័យថា តំណក់ទឹក ឬវត្ថុរាវដែលស្រក់ចុះតិចៗ ជារឿយៗ
  - បំពង់ គឺសំដៅដល់ឧបករណ៍រាងមូលទ្រវែងដែលធ្វើអំពី ឬស្សី ឬជ័រ សម្រាប់ដាក់វត្ថុរាវផ្សេងៗ។
- **ពន្យល់ន័យប្រធាន៖** ន័យចំ (អត្តានរូប) ប្រធានខាងលើមានន័យថា តំណក់ទឹក ឬវត្ថុរាវស្រក់ចុះតិចៗជារឿយៗ រមែងតែងតែពេញឧបករណ៍រាងមូលទ្រវែងធ្វើអំពីឫស្សី ឬជ័រសម្រាប់ដាក់វត្ថុរាវផ្សេងៗ។ ន័យធៀប (អត្តាបដិ

រូប) សកម្មភាពតិចៗដែលធ្វើជាប្រចាំថ្ងៃរមែង តែងទទួលបានលទ្ធផលល្អឱ្យមានការព្យាយាម អត់ធន់ តស៊ូ ។

- **បកស្រាយប្រធានៈ** តក់ៗ ពេញបំពង់៖

**ក. ន័យចំ**

- តំណក់ទឹកត្នោតស្រក់តិចៗយូរទៅអាចពេញបំពង់។
- តំណក់ទឹកភ្លៀង ឬទឹកនៅតាមទីខ្ពស់ អាចស្រក់ចុះបំពេញអាង

**ខ. ន័យធៀប**

- ការតស៊ូ អំណត់ អត់ធន់ ព្យាយាមនឹងទទួលបានជោគជ័យ
- ការសិក្សារៀនសូត្រ ការព្យាយាមរៀនសរសេរ រៀនស្តាប់ រៀនអាន រៀនគិត អនុវត្ត និងធ្វើឱ្យសិស្សមានចំណេះដឹងខ្ពស់ នឹងទទួលបាន ជោគជ័យ( ពីថ្នាក់ទាប ដល់ថ្នាក់ខ្ពស់) ការងារផ្សេងៗ
- ការងារដោយកម្លាំងកាយមាន កសិករ កម្មករ តស៊ូព្យាយាមធ្វើកិច្ចការជាប្រចាំរាល់ថ្ងៃ និងទទួលបានលទ្ធផលល្អ។
- ការងារដោយប្រាជ្ញា មន្ត្រីរាជការ អ្នកប្រាជ្ញ កវីនិពន្ធ ខិតខំបំពេញ ការងារ ដោយយកចិត្តទុកដាក់ជាប្រចាំតែងតែធ្វើឱ្យការងារមានការរីកចម្រើនធ្វើឱ្យមានកិត្តិយស។
- អាជីវករដែលរកស៊ីលក់ដូរ យកចំណេញតិចៗ យូរៗគេអាចសន្សំ ប្រាក់ចំណេញច្រើនក្លាយជាអ្នកមានជីវភាពធូរធារ។

**ឧទាហរណ៍ក្នុងអក្សរសិល្ប៍**

- **រឿងព្រះអាទិត្យថ្មីរះលើផែនដីចាស់៖** លោករដ្ឋមន្ត្រីវ័យក្មេងដែលមាន ឋានៈខ្ពង់ខ្ពស់ដោយសារការព្យាយាមរៀនសូត្រទាំងនៅក្នុងប្រទេស នៅក្រៅប្រទេសមានចំណេះដឹងខ្ពង់ខ្ពស់ក្លាយជាអ្នកដឹកនាំ

ល្អម្នាក់។ សមជាតួអង្គ ដែលបានខិតខំតស៊ូ ព្យាយាមឆ្លងកាត់ឧបសគ្គគ្រប់យ៉ាងធ្វើឱ្យខ្លួនក្លាយជាកសិករគម្រូ។

- **រឿងតេជោយ៉ត ៖** តួអង្គតេជោយ៉ត ដែលជាជនជាតិភាគតិចបានតស៊ូ ព្យាយាម ហាត់រៀនវិជ្ជាគុណពីតេជោមាសធ្វើឱ្យខ្លួនមានសមត្ថភាព ហើយត្រូវបានព្រះរាជាតែងតាំងជាមេទ័ព

- **រឿងព្រះវេស្សន្តរ៖** ព្រះវេស្សន្តរបានខិតខំសន្សំទានបារមីបន្តិចម្តងៗ ដើម្បីធ្វើមហាបរិច្ចាគរហូតបានត្រាស់ដឹងជាព្រះពុទ្ធ នៅជិតក្រោយដើម្បី ដោះទុក្ខសត្វលោក។ *កំណត់ចំណាំ( សិស្សអាចលើយករឿងផ្សេងៗទៀត រឿងកុលាបប៉ៃលិន រឿងកុមារកំព្រា រឿងមាយើង រឿងគ្រូបង្រៀនស្រុកស្រែ)។*

- **សរុបសេចក្តី** សរុបមកតំណក់ទឹកដែលស្រក់ចុះមកពីទីខ្ពស់ អាចបំពេញឧបករណ៍ដែលត្រងខាងក្រោមបានពេញយ៉ាងងាយ។ យ៉ាងណាមិញ សេចក្តីព្យាយាមរឿយៗ ជាប្រចាំក្នុងការរៀនសូត្រ ការធ្វើការងារដោយកម្លាំងកាយ កម្លាំងប្រាជ្ញាត្រូវតែទទួលបានលទ្ធផលល្អប្រសើរ។

## ៣.បញ្ចប់សេចក្តី

- **វាយតម្លៃប្រធានៈ** សុភាសិតនេះ មានអត្ថន័យដ៏ជ្រាលជ្រៅព្រោះបាន អប់រំយើងឱ្យមានការព្យាយាម តស៊ូជាជំហានៗ ទៅតាមលទ្ធភាព សមត្ថភាព របស់ខ្លួនដើម្បីសម្រេចជោគជ័យ។
- **ទស្សនៈផ្ទាល់ខ្លួនៈ** ដូចនេះ . ..................................

របទាបថ

# ប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ

## សម័យប្រឡង៖ ២៤ សីហា ២០១៥

## វិញ្ញាសា៖ អក្សរសាស្ត្រខ្មែរ ( ថ្នាក់វិទ្យាសាស្ត្រ )

## រយៈពេល៖ ៩០នាទី ពិន្ទុ ៧៥

ប្រធាន សុភាសិតមួយបានចែងថា «ការងារជាមាសប្រាក់» ។ ចូរបកស្រាយដោយរកអំណះអំណាងនៅក្នុងអក្សរសិល្ប៍មកបញ្ជាក់។

## អត្ថាធិប្បាយ

### ១.ផ្តើមសេចក្តី

- **លំនាំសេចក្តី៖** មនុស្សម្នាក់ៗតែងតែប្រាថ្នាចង់បានទ្រព្យសម្បត្តិ មាសពេជ្រ កែវកង....ដើម្បីសម្រេចតាមបំណងប្រាថ្នានេះបាន លុះណាយើងខិតខំស្វះស្វែងរកការងារត្រឹមត្រូវធ្វើជាប្រចាំ។
- **ចំណូលសេចក្តី៖** ហេតុនេះហើយបានជាមានសុភាសិតមួយពោលថា« ការងារជាមាសប្រាក់» ។
- **ចំណោទសេចក្តី៖** តើសុភាសិតខាងលើនេះមានអត្ថន័យដូចម្តេចខ្លះ?

### ២.តួសេចក្តី

- **ឃ្លាភ្ជាប់សេចក្តី**
- **ពន្យល់ពាក្យ**
    - **ការងារ៖** កិច្ចការ មុខរបរចិញ្ចឹមជីវិត
    - **មាសប្រាក់៖** លុយកាក់ ទ្រព្យសម្បត្តិ មាសពេជ្រ កែវកងទាំងឡាយ...

- **ពន្យល់ន័យប្រធានៈ** មតិប្រធានចង់បង្ហាញថា កិច្ចការទាំងឡាយដែលជាមុខរបរចិញ្ចឹមជីវិតដោយត្រឹមត្រូវ ពិតជាទទួលបាននូវទ្រព្យសម្បត្តិ មាសប្រាក់ លុយកាក់ ដែលជាតម្រូវការរបស់មនុស្សយើង។
- **បកស្រាយប្រធានៈ** «ការងារជាមាសប្រាក់»

នៅទីនេះ គឺសំដៅលើការងារទាំងឡាយណា ដែលមានភាពត្រឹមត្រូវ សុចរិត ទៀងត្រង់ សមស្របទៅតាមច្បាប់ និងមិនធ្វើឱ្យមានផលប៉ះពាល់ដល់ផលប្រយោជន៍អ្នកដទៃឡើយ។ ការងារទាំងឡាយនេះរួមមានៈ

### ក.រូបភាពការងារនៅក្នុងជីវភាព

- ការងារពាណិជ្ជករ ៖ រកស៊ីទទួលទានដើម្បីផលចំណេញ...
- ការងារកសិករៈ ការងារកសិកម្ម ដើម្បីទទួលបានទិន្នផល
- ការងារកម្មករៈ ការងារប្រើកម្លាំងបាយ ដើម្បីប្រាក់កម្រៃ
- ការងារឧស្សាហករ និងសិប្បករៈ ជាកិច្ចការច្នៃប្រឌិតបង្កើតជាសម្ភារៈ ឬឧបករណ៍ប្រើប្រាស់ ជាទីតម្រូវការរបស់មនុស្សយើង។
- កិច្ចការងារមន្ត្រីរាជការ....។

### ខ.លក្ខណៈការងារដែលទទួលបាននូវតម្លៃល្អៗសម្រាប់ជីវិតរបស់មនុស្ស

- មានភាពសុចរិតត្រឹមត្រូវ ស្របតាមទស្សនៈវិស័យរបស់មនុស្ស និងសង្គមជាតិ..
- មានការតស៊ូព្យាយាម ឈ្លាសវៃ ប៉ិនប្រសប់ មានគំនិតច្នៃប្រឌិតខ្ពស់ ...
- ការងារមនសិការប្រកបដោយក្រមសីលធម៌ខ្ពស់ បេះអធ្យាស្រ័យ គោរពច្បាប់...
- ការងារបម្រើមនុស្សជាតិ និងសង្គមជាតិ...

### គ.លទ្ធផលល្អ និងផលប្រយោជន៍

- ទទួលបានប្រាក់កំរៃ ជាអចិន្ត្រៃយ៍ សម្រាប់យកទៅផ្គត់ផ្គង់ ជីវភាពប្រចាំថ្ងៃ...
- សេដ្ឋកិច្ចគ្រួសារមានការរីកចម្រើនជាលំដាប់...
- ជីវភាពគ្រួសារមានស្ថេរភាពយូរអង្វែង...
- មនុស្សយើងមានកេរ្តិ៍ឈ្មោះល្បីល្បាញ ទទួលការគោរពពីអ្នកដទៃ...
- មានភាពឧត្តុងឧត្តមក្នុងជីវិត
- គ្រួសារទទួលបាននូវសេចក្តីសុខ សុភមង្គលគ្រប់ពេលវេលា...
- សង្គមជាតិក៏ទទួលបានសុខសន្តិភាព និងការអភិវឌ្ឍគ្រប់វិស័យ...

## ឃ.អំណះអំណាង (ឧទាហរណ៍ក្នុងអក្សរសិល្ប៍)

- **រឿងកុលាបប៉ៃលិន៖** ចៅចិត្រខិតខំបំពេញកិច្ចការជូនលោករតនៈសម្បត្តិប្រកបទៅដោយភាពត្រឹមត្រូវសុចរិត នាំឱ្យលោករតនៈសម្បត្តិពេញចិត្តបានលើកចៅចិត្រធ្វើជាកូនប្រសាររបស់លោក ដែលញ៉ាំងឱ្យជីវិតចៅចិត្រមានពន្លឺរស្មី សុភមង្គលត្រចះត្រចង់។....
- **រឿងព្រះអាទិត្យថ្មីរះលើផែនដីចាស់៖** លោករដ្ឋមន្ត្រីវ័យក្មេងខិតខំបំពេញការងារជូនជាតិញ៉ាំងឱ្យជីវិតរបស់លោកមានកិត្តិយសកេរ្តិ៍ឈ្មោះ ទទួលបានការគោរពស្រឡាញ់ពីរាស្ត្រ។...
- **រឿងទុំទាវ៖** ខ្សែជីវិតរបស់ទុំ និងពេជ្រ ដែលខិតខំសិក្សាវិជ្ជាធ្វើតោកសិល្បៈតន្ត្រី នាំឱ្យព្រះរាជាតែងតាំងជា ម៉ឺន ឯកខាងបច្ចេកទេសកិច្ចការសិល្បៈតន្ត្រីករប្រចាំរាជវាំង។...
- **រឿងគូលីកំណែន៖** ម៉ឹងខិតខំរៀនសូត្រ រហូតក្លាយជាមន្ត្រីរាជការ....
- **រឿងចៅកែចិត្តចោរ៖** ពូហំប្រព្រឹត្តការងារមិនល្អនាំឱ្យវេទនាដល់ខ្លួននិងគ្រួសារ...
- **រឿងមាយើង៖** ប្រឹងប្រែងខិតខំតស៊ូការងារល្អ នាំឱ្យក្លាយជាអ្នកមានទ្រព្យសម្បត្តិ...។

*បញ្ជាក់៖ សិស្សអាចលើកយករឿងផ្សេងៗទៀតមកបញ្ជាក់ក៏បាន ឱ្យតែបានបីរឿង ហើយមានអត្ថន័យរឿងសមស្របនឹងខ្លឹមសារប្រធានបទ។*

- **សរុបសេចក្តី** រួមសេចក្តីមក ស្របតាមការស្រាយបំភ្លឺ និងឧទាហរណ៍ដូចដែលបានបញ្ជាក់ខាងលើយើងអាចដឹងបានថា ការងារពិតជាមាសប្រាក់ពិតប្រាកដមែន ពីព្រោះថាលុយកាក់ទ្រព្យសម្បត្តិទាំងឡាយពិតជាកើតឡើងដោយការប្រកបកិច្ចការទាំងអស់ បើពុំនោះសោតទេ យើងមិនអាចទទួលបានលុយកាក់មាសពេជ្រកែវកងនោះឡើយ។

## ៣.បញ្ចប់សេចក្តី

- **វាយតម្លៃប្រធានៈ** ឆ្លងតាមការអធិប្បាយស្រាយបំភ្លឺខាងលើ យើងសន្និដ្ឋានបានថា មតិរបស់ប្រធានពិតជាមានអត្ថន័យ និងតម្លៃដ៏ល្អជ្រាលជ្រៅបំផុត ដែលបានបង្ហាញឱ្យយើងបានដឹងយ៉ាងច្បាស់ពីរាល់កិច្ចការងារទាំងឡាយគឺពិតជានាំឱ្យកើតមានទ្រព្យសម្បត្តិជាប្រាកដ។
- **ទស្សនៈផ្ទាល់ខ្លួនៈ** ដូចនេះ ក្នុងនាមយើងជាមនុស្សម្នាក់ៗ ដើម្បីទទួលបាននូវទ្រព្យសម្បត្តិ មាសពេជ្រកែវកងពោលគឺត្រូវខិតខំប្រកបការងាររិះរកកិច្ចការងារប្រកបឱ្យបានជាអចិន្ត្រៃយ៍ បើពុំនោះសោតទេលុយកាក់នឹងមិនអាចកើតមានឡើយ ។

រចនាបថ៖

# ប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ

## សម័យប្រឡង៖ ២៤ តុលា ២០១៥

## វិញ្ញាសា៖ អក្សរសាស្ត្រខ្មែរ (ថ្នាក់វិទ្យាសាស្ត្រសង្គម)

## រយៈពេល៖ ១៥០នាទី ពិន្ទុ ១២៥

ប្រធាន មានទស្សនៈមួយថែងថា«ការតស៊ូគឺជាគន្លឹះដើម្បីទទួលបានសុភមង្គល»។ ចូរបកស្រាយទស្សនៈនេះដោយយកឧទាហរណ៍ក្នុងអក្សរសិល្ប៍មកបញ្ជាក់។

## អត្ថាគំរូ

### ១.ផ្ដើមសេចក្ដី

- **លំនាំសេចក្ដី៖** និយាយទាក់ទងនឹងប្រធាន
- **ចំណូលសេចក្ដី៖** លើកបញ្ហាប្រធានមកសរសេរ
- **ចំណោទសេចក្ដី៖** ចោទសួរលើប្រធានបទ (សួរបែបប្រធានពន្យល់)

### ២.តួសេចក្ដី

- **ឃ្លាភ្ជាប់សេចក្ដី**
- **ពន្យល់ពាក្យ**
  - **ការតស៊ូ៖** ការប្រឹងប្រែងពុំព្រមជំនះគ្រប់ឧបសគ្គ ការរើបម្រះការប្រយុទ្ធប្រឆាំង។
  - **គន្លឹះ៖** ផ្លូវ មធ្យោបាយ វិធី
  - **សុភមង្គល៖** សេចក្ដីសុខកាយ សប្បាយចិត្ត សម្រេចផលដ៏ប្រសើរ
- **ពន្យល់ន័យប្រធាន៖**

- **បកស្រាយប្រធានៈ**

មានជីវិតតែងតែមានឧបសគ្គ ហើយដើម្បីជំនះឧបសគ្គទាំងនេះគេត្រូវតែធ្វើការតស៊ូប្រយុទ្ធប្រឆាំង

- សិស្សខិតខំរៀនសូត្រនាំឱ្យសម្រេចបំណង
- ប្រឹងប្រែងក្នុងការងារ ទទួលបានផលល្អ
- ប្រឹងប្រែងជំនះលើធម្មជាតិ ជួយសម្រួលដល់ការរស់នៅ
- ការស៊ូប្រយុទ្ធប្រឆាំងនឹងការជិះជាន់កេងប្រវ័ញ្ច ដើម្បីទទួលបាននូវសេរីភាព ឯករាជ្យ ចាកផុតពីទុក្ខលំបាក...។
- តស៊ូក្នុងជីវភាពរស់នៅ ទើបចាកផុតពីភាពក្រីក្រ...។

ឧទាហរណ៍ ក្នុងអក្សរសិល្ប៍

- **រឿងកុលាបប៉ៃលិន ៖** ចៅចិត្រខិតខំរៀនសូត្រ ហើយទទួលបានប្រកាសនីយបត្រមានសមត្ថភាពថែទាំងសុខភាព ចៀសផុតពីជំងឺគ្រុនចាញ់ សមត្ថភាពគ្រប់គ្រងបញ្ជីត្បូង ប្រឆាំងនឹងចោរប្លន់...។ ចៅចិត្របានខិតខំបានតស៊ូគ្រប់ឧបសគ្គក្នុងជីវិតរហូតចៅចិត្រក្លាយខ្លួនពីកម្មករតូចទាបទៅជាចៅកែវ័យក្មេងនៅបរប៉ៃលិន។
- **រឿងភូមិតិរច្ឆានៈ** តួអង្គជួន នៅ ក្រុមបាតុករ នាងនី នាងប៊ីនាងតន់ តស៊ូដោយកម្លាំងកាយ និងមតិរហូតទទួលបានសេរីភាព ដោយបារាំងបានបន្ធូរបន្ថយលើបញ្ហាជិះជាន់ គាបសង្កត់
- **រឿងព្រះអាទិត្យថ្មីរះលើផែនដីចាស់ៈ** តួងអង្គសមបានតស៊ូក្នុងជីវិតក្រលំបាកតោកយ៉ាក ទីបំផុតក្លាយជាកសិករថ្មី មានជីវភាពរស់នៅប្រសើរឡើង។

- រឿងព្រះវេស្សន្តរ៖ តួអង្គព្រះវេស្សន្តរ បានតស៊ូប្រឹងប្រែងជំនះគ្រប់ឧបសគ្គក្នុងការបំពេញទានបារមីដើម្បីសម្រេចក្នុងការត្រាស់ដឹង រកសេចក្តីសុខដល់សត្វលោកទាំងមូល។
- រឿងតេជោយ៉ត៖ តួអង្គតេជោយ៉ត តស៊ូប្រឆាំងនឹងសត្រូវឈ្លានពានយកជ័យជំនះជូនមាតុភូមិ ពិសេសការតស៊ូប្រឆាំងនឹងការរស់អើងវណ្ណៈ ក្នុងសង្គម...។

*កំណត់សម្គាល់៖ សិស្សអាចលើករឿងផ្សេងក្នុងអក្សរសិល្ប៍ខ្មែរឱ្យបានទាក់ទងនឹងប្រធាននេះ។*

- **សរុបសេចក្តី** ជារួមយើងអាចសរុបសេចក្តីបានថា ការតស៊ូប្រឹងប្រែងអំពត់ព្យាយាមរមែងតែងតែទទួលបាននូវសុភមង្គលពិតប្រាកដ។

**៣.បញ្ចប់សេចក្តី**

- **វាយតម្លៃប្រធាន៖** ពិតជាមានអត្ថន័យល្អ ក្នុងការអប់រំមនុស្សឱ្យចេះតស៊ូប្រឹងប្រែងក្នុងជីវិត....។
- **ទស្សនៈផ្ទាល់ខ្លួន៖**

រចនាបថ

# ប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ

## សម័យប្រឡង៖ ២២ សីហា ២០១៦

## វិញ្ញាសា៖ អក្សរសាស្ត្រខ្មែរ (ថ្នាក់វិទ្យាសាស្ត្រ)

## រយៈពេល៖ ៩០នាទី ពិន្ទុ ៧៥

ប្រធាន មានមតិមួយពោលថា« អត្ថបទអក្សរសិល្ប៍មានគោលដៅអប់រំមនុស្សឱ្យចេះដោះស្រាយបញ្ហា »។ ចូរបកស្រាយដោយរកឧទាហរណ៍នៅក្នុងអក្សរសិល្ប៍មកបញ្ជាក់។

## អត្ថាធិប្បាយ

### ១.ផ្តើមសេចក្តី

- **លំនាំសេចក្តី**
- **ចំណូលសេចក្តី**
- **ចំណោទសេចក្តី៖** ចោទសំបប្រធានពន្យល់

### ២.តួសេចក្តី

- **ឃ្លាភ្ជាប់សេចក្តី**
- **ពន្យល់ពាក្យ**
    - **អក្សរសិល្ប៍៖** កម្រងអត្ថបទដែលតុបតែងដោយអក្សរប្រកបដោយសិល្ប៍វិធី ឬរឿងទាំងឡាយណាដែលតាក់តែងឡើងប្រកបដោយសិល្ប៍វិធី។
    - **គោលដៅ៖** អ្វីដែលផ្តុំហើយសម្តៅរក ឬតម្រង់ទៅរក
    - **អប់រំ៖** ហ្វឹកហាត់ កែលម្អ ឱ្យប្រពៃ (ធ្វើឱ្យល្អ)
    - **បញ្ហា៖** ពាក្យ ឬសេចក្តី ដែលមានអាថ៌កំបាំង ប្រស្នា ឬចំណោទ...

- **ពន្យល់ន័យប្រធាន៖**

ទស្សន: ប្រធានមានន័យថា៖ កម្រងអត្ថបទរឿងដែលអ្នកនិពន្ធតាក់តែងឡើង សុទ្ធសឹងផ្ដុំទៅដោយខ្លឹមសារល្អ។ តម្រង់ទៅរកការហ្វឹកហាត់កែលម្អ ដោយជួយឱ្យមនុស្សចេះដោះស្រាយអាចកំចាំងនានាដែល មនុស្សបានជួប...។

- **បកស្រាយប្រធាន៖**

**១.កម្រងអត្ថបទអក្សរសិល្ប៍មានគោលដៅអប់រំមនុស្ស ឱ្យចេះដោះស្រាយបញ្ហា**

**អក្សរសិល្ប៍បានបង្ហាញបញ្ហាដែលមនុស្សជួបប្រទះមានច្រើនដូចជា៖**

- បញ្ហាសង្គម
  - បញ្ហាភាពក្រីក្រ
  - បញ្ហាសុភមង្គល
  - បញ្ហាសិទ្ធិមនុស្ស
  - បញ្ហាជិះជាន់
  - បញ្ហាកេងប្រវ័ញ្ច
  - បញ្ហាវប្បធម៌ អរិយធម៌
- បញ្ហាធម្មជាតិ
  - បញ្ហាទឹកជំនន់
  - គ្រោះធម្មជាតិ

**២.អក្សរសិល្ប៍លើកបញ្ហាទាំងអស់នេះមកបង្ហាញមានគោលដៅអប់រំមនុស្សចេះដោះស្រាយបញ្ហាដូចជា៖**

- មានប្រាជ្ញាឈ្លាសវៃ
- មិនប្រើហិង្សា
- ចេះតស៊ូ
- ឧស្សាហ៍ព្យាយាម

- ត្រិះរិះ ពិចារណា វិភាគ
- អង់អាចក្លាហាន
- ពិសេសគំរូល្អៗក្នុងអក្សរសិល្ប៍ត្រូវទទួលយកចំណុចអាក្រក់អវិជ្ជមាន គួរចៀសវាង

## ៣.លើកឧទាហរណ៍ក្នុងស្នាដៃអក្សរសិល្ប៍ខ្មែរ

### ក.អក្សរសិល្ប៍ប្រជាប្រិយ

- រឿងអ្នកតាទឹកអ្នកតាភ្នំៈ បង្ហាញពីបញ្ហាទឹកជំនន់ អប់រំឱ្យចេះដោះស្រាយបញ្ហាទឹកជំនន់
- រឿងធនញ្ជ័យៈ បង្ហាញពីការកេងប្រវ័ញ្ច ការប្រើអំណាចផ្ដាច់ការ អប់រំឱ្យចេះបញ្ហាឈ្លាសវៃក្នុងការដោះស្រាយបញ្ហា...
- រឿងដើមកំណើតរន្ទះ

### ខ.អក្សរសិល្ប៍បុរាណ

- រឿងព្រះវេស្សន្តរ
- រឿងរាមកេរ្តិ៍
- រឿងពុទ្ធិសែន...

### គ.អក្សរសិល្ប៍ទំនើប

- រឿងភូមិតិរច្ឆាន
- រឿងព្រះអាទិត្យថ្មីរះលើផែនដីចាស់
- រឿងគូលីកំណែន...

- **សរុបមតិ( ៥ពិន្ទុ )**

**សរុបសេចក្ដីមក** អក្សរសិល្ប៍ពិតជាមានគោលដៅអប់រំមនុស្សឱ្យចេះដោះស្រាយបញ្ហាមែនព្រោះគ្រប់ ស្នាដៃអក្សរសិល្ប៍ទាំងបីចលនាសុទ្ធតែបង្ហាញ ហើយយកបញ្ហាទាំងនោះមកជាគំនិតដល់ យើងឱ្យចេះដោះស្រាយបញ្ហាក្នុងជីវភាព និងសង្គមបាន។

## ៣.បញ្ចប់សេចក្តី

- **វាយតម្លៃប្រធានៈ** ឆ្លងទៅតាមការអធិប្បាយស្រាយបំភ្លឺខាងលើ យើងសន្និដ្ឋានបានថា មតិរបស់ប្រធានពិតជាមានអត្ថន័យ និងតម្លៃដ៏ល្អ ដែលបានបង្ហាញឱ្យយើងឃើញពីតួនាទីដ៏សំខាន់របស់អក្សរសិល្ប៍ដែលរួមចំណែកក្នុងការអប់រំ មនុស្សនិងសង្គម។
- **ទស្សនៈផ្ទាល់ខ្លួនៈ** ដូចនេះ ក្នុងនាមយើងជាអ្នកសិក្សាគួរគប្បីយល់ឱ្យបានច្បាស់ពីគោលបំណងនៃអក្សរសិល្ប៍នីមួយៗ និងចេះច្នៃដកស្រង់បទពិសោធន៍ដែលមានក្នុងអក្សរសិល្ប៍មករួមចំណែកធ្វើដំណោះស្រាយ បញ្ហាដែលបានជួបប្រទះដោយសន្តិវិធី...។

របទាបថ

# ប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ

## សម័យប្រឡង៖ ២២ សីហា ២០១៦

## វិញ្ញាសា៖ អក្សរសាស្ត្រខ្មែរ ( ថ្នាក់វិទ្យាសាស្ត្រសង្គម )

## រយៈពេល៖ ១៥០នាទី ពិន្ទុ ១២៥

ប្រធាន មានទស្សនៈមួយពោលថា« ការអប់រំគឺជាសិទ្ធិសេរីភាពដែលបើកផ្លូវឱ្យមនុស្សសម្រេចបានភាពថ្លៃថ្នូរក្នុងជីវិត »។ ចូរបកស្រាយទស្សនៈនេះដោយរកឧទាហរណ៍ក្នុងអក្សរសិល្ប៍មកបញ្ជាក់។

## អត្ថាធិប្បាយ

### ១.ផ្តើមសេចក្តី

- **លំនាំសេចក្តី**
- **ចំណូលសេចក្តី**
- **ចំណោទសេចក្តី៖** លោកលើកប្រធានពន្យល់

### ២.តួសេចក្តី

- **ឃ្លាភ្ជាប់សេចក្តី**
- **ពន្យល់ពាក្យ**
    - ***ការអប់រំ៖*** ការណែនាំទូន្មាន ប្រៀនប្រដៅ ក្រើនរំលឹកឱ្យបានល្អប្រពៃ ដើម្បីកែប្រែបុគ្គលិកលក្ខណៈរបស់មនុស្ស។
    - ***សិទ្ធិសេរីភាព៖*** អំណាចបុគ្គល ដែលអាចធ្វើអ្វីៗបានសមស្របតាមផ្លូវច្បាប់។

- **ភាពថ្លៃថ្នូរ៖** ភាពល្អប្រសើរថ្លៃថ្លា ឧដុង្គឧត្តមក្នុងជីវិត។

- **ពន្យល់ន័យប្រធាន៖** ដូច្នេះន័យប្រធានគឺណែនាំទូន្មានប្រៀនប្រដៅ ក្រើនរំលឹកឱ្យបានល្អប្រពៃដើម្បីកែប្រែបុគ្គលិកលក្ខណៈមនុស្ស គឺជាអំណាចនៃបុគ្គលអាចធ្វើអ្វីៗបានស្របតាមផ្លូវច្បាប់ ដើម្បីឱ្យមានភាពល្អប្រសើរថ្លៃថ្លាឧដុង្គឧត្តមក្នុងជីវិត។

- **បកស្រាយប្រធាន៖**

## ក.បំភ្លឺន័យទូទៅ

មនុស្សម្នាក់ៗអាចធ្វើឱ្យជីវិតរបស់ខ្លួនទទួលបានភាពថ្លៃថ្នូដោយសារបុគ្គលមានសិទ្ធទទួលបានការអប់រំជាមាគ៌ាដូចជាការអប់រំផ្នែកសីលធម៌ គុណធម៌ សុជីវធម៌ និងចំណេះជំនាញ ផ្សេងៗព្រមទាំងអប់រំឱ្យស្រឡាញ់ជាតិមាតុភូមិ អរិយធម៌ វប្បធម៌ បរិស្ថាន យុត្តិធម៌...។

## ខ.បំភ្លឺន័យប្រធាន

ការអប់រំនេះស្តែងឡើងតាមរយៈការអប់រំក្នុងគ្រួសារ ការអប់រំក្នុងសាលារៀន ការអប់រំក្នុងសង្គម។

- **ការអប់រំក្នុងគ្រួសារ** គឺឪពុកម្តាយតែងតែអប់រំណែនាំឱ្យកូនចៅមានសីលធម៌ គុណធម៌ សុជីវធម៌។ ក្នុងគ្រួសារមួយ បើកូនចេះស្តាប់ដំបូន្មានរបស់ឪពុកម្តាយ នាំឱ្យកូននិងទទួលបានជោគជ័យក្នុងជីវិត។
- **ការអប់រំក្នុងសាលារៀន៖** លោកគ្រូអ្នកគ្រូតែងតែអប់រំកូនសិស្ស ឱ្យមានចំណេះជំនាញ មានសីលធម៌ គុណធម៌ សុជីវធម៌ល្អ ចេះស្រឡាញ់ទឹកដីវប្បធម៌ទំនៀមទម្លាប់...
- **ការអប់រំក្នុងសង្គម៖** ការអប់រំឱ្យមនុស្សមានបទពិសោធន៍ ចំណេះដឹង ស្រឡាញ់សន្តិភាព យុត្តធម៌ ភាពថ្លៃថ្នូរ និងចេះដោះស្រាយបញ្ហាក្នុងជីវិត ។

## គ.ឧទាហរណ៍

- ការអប់រំក្នុងគ្រួសារ
  - **រឿងកុមាកំព្រា៖** តួអង្គកុមារប្អូន យកគំរូនិងធ្វើតាមបណ្តាំឪពុក ក្នុងការធ្វើជុចតាំងពីដាក់ត្រី ដាក់ដំរី ចុងក្រោយក្លាយជាស្តេច។
  - **រឿងកុលាបប៉ៃលិន៖** តួអង្គចៅចិត្រស្តាប់តាមបណ្តាំឪពុក « ខ្លួនទីពឹងខ្លួន» ចុងក្រោយក្លាយជាអ្នកមានទ្រព្យជាកូនប្រសារលោកហ្លួងរតនៈសម្បត្តិ។
- ការអប់រំក្នុងសាសនា
  - **រឿងរាមកេរ្តិ៍៖** តួអង្គព្រះឬាមបានហាត់រៀនពីឥសីពិស្វាមិត្រចេះចប់គម្ពីរត្រៃវេទ មានសមត្ថភាពលើកធ្នូសរួច ឈ្នះទេវឋានទាំងបីទទួលបាននាងសីតាជាមហេសី។
  - **រឿងទុំទាវ៖** ទុំរៀនសូត្រ ពេជ្ររៀនបុំ ខ្លុយ ចេះធ្វើតោក...
- ក្នុងសង្គម
  - **រឿងគូលីកំណែាន៖** តួអង្គម៉ឹងរៀនចប់បានការងារធ្វើជាអ្នករាជការបេញតស៊ូក្នុងចលនាតស៊ូខ្មែរឥស្សរៈដើម្បីទាមទារឯករាជ្យ...។
  - **រឿងធនញ្ជ័យ៖** ដកស្រង់ចំណេះដឹងពីសង្គម ទទួលបានចំណេះដឹងអាចដោះស្រាយប្រស្នាចិនរួច...។
  - **រឿងព្រះអាទិត្យថ្មីរះលើផែនដីចាស់៖** តួអង្គសមឆ្លងកាត់បទពិសោធន៍ការងារ ជាកម្មករផង ជាកសិករផង ចុងក្រោយជាកសិករគម្រូ និងជាគណៈកម្មការកងឃុំបរិវេ។

*ពង្រីកគំនិត៖* *ផ្ទុយទៅវិញ ប្រសិនបើមនុស្សមិនទទួលបានការអប់រំនោះ មនុស្សពុំអាចរស់នៅក្នុងភាពថ្លៃថ្នូរបានឡើយ។ (បេក្ខជនអាចលើកឧទាហរណ៍បញ្ជាក់)។*

- **សរុបសេចក្តីមក**

## ៣.បញ្ចប់សេចក្តី

- **វាយតម្លៃប្រធានៈ** ទស្សនៈប្រធានមានខ្លឹមសារល្អក្នុងការអប់រំក្នុងការអប់រំសិស្សនិស្សិត និងមនុស្សទូទៅឱ្យយល់ពីសិទ្ធក្នុងការទទួលយកការអប់រំសម្រាប់កែប្រែទស្សនៈជីវិតរបស់ខ្លួន ដើម្បីរស់នៅក្នុងសង្គមមួយមានភាពថ្លៃថ្នូរ។
- **ទស្សនៈផ្ទាល់ខ្លួនៈ** មនុស្សត្រូវតែមានសិទ្ធិទទួលបានការអប់រំ ដើម្បីធ្វើឱ្យជីវិតរស់នៅបានក្នុងភាពថ្លៃថ្នូរ។

របនាបថ

# ប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ

## សម័យប្រឡង៖ ២១ សីហា ២០១៧

## វិញ្ញាសា៖ អក្សរសាស្ត្រខ្មែរ ( ថ្នាក់វិទ្យាសាស្ត្រ )

## រយៈពេល៖ ៩0នាទី  ពិន្ទុ ៧៥

ប្រធាន មានទស្សនៈមួយថែងថា« ការសិក្សាពេញមួយជីវិតគឺជារបៀបនៃការអប់រំក្នុងសតវត្សទី២១ »។ ចូរអធិប្បាយពន្យល់ទស្សនៈខាងលើនេះដោយលើកឧទាហរណ៍មកបញ្ជាក់។

## អត្ថាគំនែង

### ១.ផ្ដើមសេចក្ដី

- **លំនាំសេចក្ដី៖** ការរស់នៅរបស់មនុស្សតែងតែមានកាតព្វកិច្ចសិក្សារៀនសូត្រ ...
- **ចំណងលសេចក្ដី៖** ក្នុងបំណងទទួលបាននូវពុទ្ធិ និងការអប់រំ...ធនធានមនុស្ស...
- **ចំណោទសេចក្ដី៖** តើមតិខាងលើមានន័យដូចម្ដេចខ្លះ?

### ២.តួសេចក្ដី

- **ឃ្លាភ្ជាប់សេចក្ដី**
- **ពន្យល់ពាក្យ** ( បើសិស្សពន្យល់បានបី ត្រូវបានពិន្ទុពេញ )
    - កាសិក្សា៖ ការស្រាវជ្រាវរៀនសូត្រដើម្បីស្វែងរកនូវចំណេះ និងបទពិសោធន៍នានា...
    - របៀប៖ វិធី មធ្យោបាយ  ឬយន្តការប្រព្រឹត្តទៅ...

- ○ អប់រំ៖ ការទូន្មាន ប្រៀនប្រដៅឱ្យប្រព្រឹត្ត ទង្វើល្អត្រឹមត្រូវ
- ○ សតវត្សទី២១៖ យុគ្គសម័យដែលកំពុងដំណើរការបច្ចុប្បន្ន

- **ពន្យល់ន័យប្រធាន៖** ទស្សនៈប្រធានមានន័យថា ការស្រាវជ្រាវ រៀនសូត្រដើម្បីស្វែងរកចំណេះដឹងយូរអង្វែង ជាយន្តការ ឬមធ្យោបាយអប់រំទូន្មានប្រៀនប្រដៅមនុស្សទៅក្នុងយុគ្គសម័យបច្ចុប្បន្នឱ្យក្លាយទៅជាធនធានមនុស្ស។
- **បកស្រាយប្រធាន៖**

**ក.លក្ខណៈនៃការសិក្សា** ៖ នៅក្នុងការសិក្សារៀនសូត្រ ដើម្បីទទួលបាននូវចំណេះវិជ្ជាជ្រៅជ្រះលុះត្រាតែអនុវត្តទៅតាមគោលការណ៍៖

- ○ ត្រូវចេះសិក្សារៀនសូត្រតាមក្បួនច្បាប់គម្ពីរ ទ្រឹស្តី រូបមន្ត និងតាមរយៈកម្រងសៀវភៅនានាជាច្រើន ដែលអ្នកនិពន្ធបានតាក់តែងកន្លងមក « សៀវភៅគឺជាផ្កាសម្រាប់ផ្គេរចំណេះដឹង»។
- ○ ត្រូវអនុវត្តទៅតាមអង្គបួនរបស់ពុទ្ធឱវាទ គឺ សុ. ចិ. បុ. លិ.
  - សុ ( សុត្តៈ) សិស្សានុសិស្សត្រូវស្តាប់បានជិតដល់បំផុតតាមរយៈការពន្យល់បង្រៀនរបស់លោកគ្រូអ្នកគ្រូទាំងអស់។
  - ចិ.(ចិន្តៈ) ក្នុងនាមយើងជាសិស្សត្រូវចេះគិតពិចារណាទៅលើអត្ថន័យ ឬខ្លឹមសារមេរៀនទាំងអស់ដែលលោកគ្រូអ្នកគ្រូបានបង្រៀន។
  - បុ.(បុច្ឆៈ) បើចូល់មិនច្បាស់ ត្រូវចេះសាកសួរដល់លោកគ្រូអ្នកគ្រូ
  - លិ. (លិខៈ) ក្រោយពីបានយល់ច្បាស់ សិស្សានុសិស្សទាំងអស់ត្រូវកត់ត្រាទុកជាមេរៀនជាឯកសារ សម្រាប់អនុវត្តនាពេលក្រោយៗ។
  - និងគំនិតផ្សេងៗទៀតដែលពាក់ព័ន្ធ.ដូចជារៀនពីអ៊ីនធើណេត

**ខ.ទិសដៅនៃការសិក្សា៖** «ការសិក្សាពេញមួយជីវិត»

- ការសិក្សាត្រូវចំណាយពេលអស់រយៈកាលដ៏យូរ ទើបយើងទទួលបានចំណេះដឹង...
- ត្រូវរៀនហើយរៀនទៀត ពោលគឺត្រូវរៀនគ្រប់ផ្នែកទាក់ទងទៅនឹងបំណិនជីវិតក្នុងការរស់នៅ
- ការរៀនត្រូវចាប់ផ្ដើមរៀនតាំងពីមត្តេយ្យ រហូតដល់បរិញ្ញាបត្រ អនុបណ្ឌិត បណ្ឌិត...
- ដើម្បីបំពេញតម្រូវការចាំបាច់ក្នុងការរស់នៅ
- ដើម្បីកសាងខ្លួនឱ្យក្លាយទៅជាឧត្តមជន
- ជួយដល់សង្គមជាតិឱ្យមានការរីកចម្រើនជឿនលឿន ព្រោះមានធនធានមនុស្សច្រើន
- និងគំនិតត្រឹមត្រូវផ្សេងទៀតដែលពាក់ព័ន្ធ (ការរៀនសូត្រពីការងារ)

**គ.លទ្ធផលនៃការសិក្សា៖** «ការសិក្សាពេញមួយជីវិត គឺជារបៀបនៃការអប់រំក្នុងសតវត្សទី២១» ៖ ស្របទៅនឹងបរិបទនេះ សិស្សានុសិស្សត្រូវសិក្សាបំណិនជីវិត៖

- មានជំនាញផ្សេងៗសម្រាប់ប្រកបរបររកស៊ីទទួលបានទាន
- មានចំណេះដឹងខាងភាសាអន្តរជាតិ
- មានបំណិនលេខនព្វន្តសម្រាប់គិតគូរ បូក ដក ស៊ីសង
- មានបំណិនដោះស្រាយបញ្ហា ដែលបានកើតមានឡើងក្នុងសង្គម
- មានបំណិនចេះគិតត្រិះរិះពិចារណាបានដឹង នូវអ្វីដែលល្អអាក្រក់...
- មានបំណិនវប្បធម៌៖ ចេះថែរក្សាវប្បធម៌ជាតិ និងចេះធ្វើការសំយោគវប្បធម៌អន្តរជាតិដើម្បីឱ្យមានផលរីកចម្រើន...។

- និងគំនិតត្រឹមត្រូវផ្សេងទៀតដែលពាក់ព័ន្ធ។

អំណះអំណាង

ក.ក្នុងសង្គម

- **សង្គមប្រវត្តិ៖** អ្នកប្រវត្តិវិទូបានលើកយកបញ្ហាពីខ្សែជីវិតសម្ដេចព្រះសង្ឃរាជ ជួនណាត ដែលព្រះអង្គបានសិក្សារពេញមួយជីវិត។
- សង្គមបច្ចុប្បន្ន៖ មនុស្សយើងជាច្រើននៅក្នុងសតវត្សទី២១ នេះបានក្លាយជាវិស្វករជំនាញខាងសាងសង់...បានក្លាយទៅជាអាជីវករ...ក្លាយជាអ្នកវិទ្យាសាស្ត្រ...បង្កើតគ្រឿងអេឡិចត្រូនិចទំនើបៗ...។

ខ.ក្នុងអក្សរសិល្ប៍

- **រឿងកុលាបប៉ៃលិន៖** ចៅចិត្រមានចំណេះដឹង ជំនាញខាងលេខនព្វន្ត ចេះភាសាបារាំងយ៉ាងស្ទាត់ជំនាញ...
- **រឿងមាលាដួងចិត្ត៖** ទីឃាវុធ ចេះភាសាថៃច្បាស់លាស់...
- **រឿងព្រះអាទិត្យថ្មីរះលើផែនដីចាស់៖** លោករដ្ឋមន្ត្រីទើបនឹងមកពីសិក្សានៅប្រទេសបារាំង...
- **រឿងទុំទាវ៖** ទុំ ពេជ្រ បានខិតខំសិក្សាទាំងផ្លូវលោក ផ្លូវធម៌ ជំនាញវិជ្ជាជីវៈ...
- **រឿងរាមកេរ្តិ៍...**
- **រឿងតេជោយ៉ត...**
- **ផ្កាស្រពោន...**

*នៅក្នុងឧទាហរណ៍ បើសិស្សលើក្នុងសង្គម និងអក្សរសិល្ប៍ រឿងអ្វីក៏បានឱ្យតែបានបីត្រឹមត្រូវសមហេតុផល គឺនឹងត្រូវបានពិន្ទុពេញ។*

**សរុបមតិ** សរុបសេចក្ដីមក ការសិក្សារៀនសូត្រគឺវាពិតជាឥតដែនកំណត់ប្រាកដមែនព្រោះការសិក្សាជានិច្ចនិរន្តរ៍ជុំរុញឱ្យមនុស្សមានការអភិវឌ្ឍចំណេះដឹងចំណេះធ្វើកាន់តែមានប្រសិទ្ធភាពខ្ពស់។

## ៣.បញ្ចប់សេចក្ដី

- **វាយតម្លៃប្រធានៈ** ឆ្លងតាមការបកស្រាយ មតិរបស់ប្រធានពិតជាមានតម្លៃនិងអត្ថន័យដ៏ល្អជ្រាលជ្រៅបំផុត ដែលបានបង្ហាញឱ្យឃើញពីរបៀបរបបក្នុងការអប់រំដើម្បីឱ្យបានក្លាយជាធនធានមនុស្សក្នុងសង្គមបច្ចុប្បន្ន។
- **ទស្សនៈផ្ទាល់ខ្លួនៈ** ក្នុងនាមយើងជាអ្នកសិក្សាគ្រប់ៗរូបត្រូវតែនាំគ្នាសិក្សារៀនសូត្រគ្រប់ពេល

របទាបថ

# ប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ

## សម័យប្រឡង៖ ២១ សីហា ២០១៧

## វិញ្ញាសា៖ អក្សរសាស្ត្រខ្មែរ ( ថ្នាក់វិទ្យាសាស្ត្រសង្គម )

## រយៈពេល៖ ១៥០នាទី  ពិន្ទុ ១២៥

ប្រធាន ក្នុងច្បាប់ល្បើកថ្មី អ្នកភិរម្យភាសាអ៊ូហៅម៉ុយបានពោលថា « បម្រើមើលពុត ប្រាជ្ញាឱ្យមុត ស្មារតីឱ្យមាន បើខ្លាចឱ្យប្រាជ្ញ បើខ្លាចឱ្យហ៊ាន ចង់បានរបៀន កុំអៀនកុំខ្មាស »។ ចូរបកស្រាយដោយរកឧទាហរណ៍ក្នុងអក្សរសិល្ប៍មកបញ្ជាក់។

## អត្ថាធិប្បាយ

### ១.ផ្តើមសេចក្តី

- **លំនាំសេចក្តី៖** និយាយទាក់ទងនឹងប្រធាន
- **ចំណូលសេចក្តី៖** លើកយកបញ្ហាប្រធានមកសរសេរ
- **ចំណោទសេចក្តី៖** ចោទសួរលើប្រធានបទ( សួរបែបប្រធានពន្យល់ )

### ២.តួសេចក្តី

- **ឃ្លាភ្ជាប់សេចក្តី**
- **ពន្យល់ពាក្យ**
    - **ពុត៖** កិច្ចកល មាយា ល្បិច
    - **មុត៖** នៅទីនេះសំដៅលើភាពច្បាស់លាស់ ឈ្លាសវៃ ភ្លឺថ្លា
    - **ខ្លៅ៖** មិនចេះ មិនដឹង មិនយល់ ល្ងិតល្ងង់
    - **ប្រាជ្ញ៖** ឈ្លាសវៃ វៃឆ្លាត ប៉ិនប្រសប់

- **របៀន៖** ចំណេះដែលចេះពីការរៀនសូត្រ

- **ពន្យល់ន័យប្រធាន៖**

ទស្សនៈប្រធានមានន័យថា មុននឹងយកនរណាម្នាក់មកបម្រើការ គោរពឱ្យយើងមានភាពឈ្លាសវៃ ឱ្យមានស្មារតីក្នុងការមើលឫកពារមារយាទ ល្បិចកល ហើយបើចង់បានចំណេះទាល់តែឈ្លាសវៃ ក្លាហាន ហ៊ានសួរកុំអៀនខ្មាស។

- **បកស្រាយប្រធាន៖**

**ក. គំនិតសំខាន់ទី១**

« បម្រើមើលពុត ប្រាជ្ញាឱ្យមុត ស្មារតីឱ្យមាន »មានន័យថានៅក្នុងជីវភាពរស់នៅ មនុស្សម្នាក់ៗ តែងមាន កិច្ចការច្រើនដែលបំពេញតាមភារកិច្ចជួនកិច្ចការខ្លះអាចធ្វើបានដោយខ្លួនឯង ឯការងារខ្លះទៀតត្រូវពឹងពាក់លើអ្នកដទៃឱ្យជួយ ឬមកបម្រើ មិនថាការងារផ្ទះ ឬការងារក្រុមហ៊ុនឡើយ។ ម្ចាស់ផ្ទះ ម្ចាស់ក្រុមហ៊ុន ឬថ្នាក់ដឹកនាំស្ថាប័នរាជការគប្បីជ្រើសរើសអ្នកបម្រើ ឬបុគ្គលិកឱ្យមកជួយកិច្ចការរបស់ខ្លួន ត្រូវចេះពិនិត្យឫកពារ មារយាទ ពុតត្បុត អ្នកបម្រើ ឬបុគ្គលិកនោះជាមុនសិន ដើម្បីជៀសវាងក្តីអន្តរាយណាមួយលើខ្លួនយើង។

ម្យ៉ាងវិញទៀតប្រាសមកវិញ បើនរណាម្នាក់តៅបម្រើការងារឱ្យគេក៏គួរតែពិនិត្យមើលកិរិយាមារយាទ ពុតត្បុត ឬចំណង់ចំណូលចិត្តរបស់ចៅហ្វាយនាយជាមុនផងដែរ ទើបអាចទទួលបានការពេញចិត្ត ឬអាចជៀសផុតពីការចាញ់បោក ឬទុក្ខទោសពីម្ចាស់ ឬចៅហ្វាយ។

**ឧទាហរណ៍ក្នុងអក្សរសិល្ប៍**

*អក្សរសិល្ប៍ប្រជាប្រិយ*

- ***រឿងឪពុកក្មេករើសកូនប្រសារ៖*** បុរសទី១ មិនមើពុតរបស់ឪពុកក្មេកទើបបរាជ័យ ។ឯបុរសទី២ ដឹងពីពុត ឬកិរិយាមារយាទរបស់ឪពុកក្មេកក៏ទទួលជោគជ័យ ។ រីឯតាជាឪពុកមិនចេះមើពុតបុរសទី២ ក៏ទទួលបរាជ័យ។

- **រឿងមាយើង៖** ចៅមាណពមិនយល់ពីពុត ឬកិរិយាបថស្ដេច ទើបមាណពស្ទើរបង់ជីវិត...
- **រឿងធនញ្ជ័យ៖** សេដ្ឋីមិនមើលពុតធនញ្ជ័យទើបធ្វើឱ្យវិនាស...

អក្សរសិល្ប៍បុរាណ

- **រឿងរាមកេរ្តិ៍៖** ព្រះរាមមិនដឹងពីពុតត្បុត របស់នាងអតុល័យ ដែលប្រើល្បិចបំបែកបំបាក់គ្រួសារខ្លួន...

អក្សរសិល្ប៍ទំនើប

- **រឿងកុលាបប៉ៃលិន៖** លោកហ្លួងរតនៈសម្បត្តិ យល់ពីកិរិយាមារយាទរបស់ចៅចិត្រ ប្រគល់ការងារឱ្យ ធ្វើលទ្ធផលទទួលបានជោគជ័យ...
- **រឿងចៅកែចិត្តចោរ...**
- **រឿងព្រះអាទិត្យថ្មីរះលើផែនដីចាស់...**
- **រឿងតេជោយ៉ត...**

## ខ. គំនិតសំខាន់ទី២

« បើខ្លាចឱ្យប្រាជ្ញ បើខ្លាចឱ្យហ៊ាន ចង់បានរៀន កុំអៀនកុំខ្មាស » មានន័យថាមនុស្សម្នាក់ៗនៅក្នុងសង្គម មានភ្ជាប់នូវភាពល្ងិតល្ងង់ជាមួយខ្លួន ហើយជាសំណូមពរពួកគេតែងតែចង់បាននូវចំណេះដឹងសព្វសារពើ ដើម្បីសម្រេចបាននូវគោលដៅខាងលើនេះ មនុស្សចាំបាច់ស្វែងរកការសិក្សារៀនសូត្រ ប្រកបដោយភាពឈ្លាសវៃ រហ័សរហួន ហ៊ានសួរ ហ៊ានឆ្លើយ ចាំមើលស្រង់បទពិសោធន៍ពីអ្នកដទៃ...។

**ឧទាហរណ៍ក្នុងអក្សរសិល្ប៍**

អក្សរសិល្ប៍ប្រជាប្រិយ

- អ្នកក្រនៅក្បែរផ្ទះសេដ្ឋីធ្វើត្រាប់តាមសេដ្ឋី៖ អ្នកក្របានយកគំរូរបស់សេដ្ឋីក្លាយជាអ្នកមាន

អក្សរសិល្ប៍បុរាណ

- រឿងរាមកេរ្តិ៍៖ ព្រះរាមបានទៅរៀនយុទ្ធសិល្ប៍ជាមួយឥសីពិស្វាមិត្រ ចេះក្បួនច្បាប់យុទ្ធសិល្ប៍...

អក្សរសិល្ប៍ទំនើប

- រឿងទុំទាវ៖ ទុំរៀនសូត្រនៅវត្តវិហារធំ នាំឱ្យចេះស្មូត្រ មើលសាស្ត្រា ធ្វើតោក...
- រឿងផ្កាស្រពោន៖ ប៊ុន ធឿន...
- រឿងចៅកែចិត្តចោរ៖ ផានិត...

**សរុបមតិ** សរុបសេចក្តីមក អក្សរសិល្ប៍ពិតជាមានគោលដៅអប់រំមនុស្សឱ្យចេះដោះស្រាយបញ្ហាមែន ព្រោះគ្រប់ស្នាដៃអក្សរសិល្ប៍ខ្មែរទាំងបីចលនា សុទ្ធតែបង្ហាញនូវបញ្ហា ហើយយកបញ្ហាទាំងនោះមកជាគំនិតដល់ យើងឱ្យចេះដោះស្រាយបញ្ហាក្នុងជីវភាព និងសង្គមបាន។

**៣.បញ្ចប់សេចក្តី**

- **វាយតម្លៃប្រធាន៖** ឆ្លងទៅតាមការអធិប្បាយស្រាយបំភ្លឺខាងលើ យើងសន្និដ្ឋានបានថា មតិរបស់ប្រធានពិតជាមានអត្ថន័យ និងតម្លៃដ៏ល្អ ដែលបានបង្ហាញ ឱ្យយើងឃើញពីតួនាទីដ៏សំខាន់របស់អក្សរសិល្ប៍ដែលរួមចំណែកក្នុងការអប់រំ មនុស្សនិងសង្គម។
- **ទស្សនៈផ្ទាល់ខ្លួន៖** ដូចនេះ ក្នុងនាមយើងជាអ្នកសិក្សាគួរតែយល់ឱ្យបានច្បាស់ពីគោលបំណងនៃអក្សរសិល្ប៍នីមួយៗនិងចេះច្នៃដកស្រង់បទពិសោធន៍ ។

របនាបថ

# ប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ

## សម័យប្រឡង៖ ២០ សីហា ២០១៨

## វិញ្ញាសា៖ អក្សរសាស្ត្រខ្មែរ ( ថ្នាក់វិទ្យាសាស្ត្រពិត )

## រយៈពេល៖ ៩០នាទី ពិន្ទុ ៧៥

ប្រធាន មានទស្សនៈមួយចែងថា
« សេចក្ដីព្យាយាមគង់បានសម្រេច »។
ចូរបកស្រាយដោយរកអំណះអំណាងក្នុងអក្សរសិល្ប៍មកបញ្ជាក់។

## អត្ថាធិប្បាយ

### ១.ផ្ដើមសេចក្ដី

- **លំនាំសេចក្ដី៖** មនុស្សយើងទាំងឡាយតែងចង់បាននូវការសម្រេច ជោគជ័យអ្វីៗទាំងអស់។
- **ចំណូលសេចក្ដី៖** បញ្ចូលប្រធាន
- **ចំណោទសេចក្ដី៖** តើពំនោលខាងលើមានអត្ថន័យដូចម្ដេចខ្លះ?( ចោទបែបពន្យល់ )

### ២.តួសេចក្ដី

- **ឃ្លាភ្ជាប់សេចក្ដី**
- **ពន្យល់ពាក្យ**
  - *សេចក្ដីព្យាយាម៖* សេចក្ដីខិតខំប្រឹងប្រែង ការប្រឹងប្រែង
  - *សម្រេច៖* ធ្វើឱ្យដាច់ស្រេច ធ្វើឱ្យបានការ ឱ្យសមស្របទៅតាមបំណង
- **ពន្យល់ន័យប្រធាន៖** មតិរបស់ប្រធានមានន័យថា សេចក្ដីប្រឹងប្រែង គឺគង់តែបានធ្វើឱ្យកើតការ បានការ សមស្របទៅតាមបំណងប្រាថ្នា។

- **បកស្រាយប្រធានៈ**

**ក.គំនិតសំខាន់** « សេចក្តីព្យាយាមគង់បានសម្រេច »

ប្រភេទនៃសេចក្តីព្យាយាម

- ព្យាយាមរៀនសូត្រ
- ព្យាយាមធ្វើការងារប្រកបមុខរបរចិញ្ចឹមជីវិត
- ព្យាយាមដោះស្រាយបញ្ហាដែលបានកើតឡើង
- ជម្នះរាល់គ្រប់ឧបសគ្គ
- ព្យាយាមក្នុងការតស៊ូ ប្រយុទ្ធប្រឆាំងគ្រោះធម្មជាតិ
- ព្យាយាមលុបបំបាត់នៃការរើសអើង
- ព្យាយាមតស៊ូកម្ចាត់សត្រូវ
- ព្យាយាមក្នុងការធ្វើទង្វើល្អ ត្រឹមត្រូវតាមរយៈផ្លូវកាយ វាចា ចិត្ត
- ព្យាយាមគោរពច្បាប់របស់ប្រទេស
- ព្យាយាមស្វែងរកសេចក្តីយុត្តធម៌....( សិស្សអាចលើកគំនិតសំខាន់ផ្សេងៗ ពីនេះបាន )

លក្ខណៈនៃការព្យាយាម

- ដោយសុចរិតយុត្តិធម៌
- ដោយតស៊ូអំណត់ អត់ធ្មត់
- ប្រើសអស់កម្លាំងកាយចិត្ត ដោយគំនិត សុទិដ្ឋិនិយម ដោយភាពជឿជាក់ដោយមានការកំណត់គោលដៅច្បាស់លាស់
- ដោយមានសីលធម៌ល្អ...( សិស្សអាចលើគំនិតសំខាន់ផ្សេងៗ ពីនេះបាន )

អត្ថប្រយោជន៍នៃការព្យាយាម

- ទទួលជោគជ័យ លើការងារដែលបានធ្វើទាំងអស់

- កំណត់គោលដៅទៅតាមសេចក្តីប្រាថ្នា
- ដឹកនាំមនុស្សឆ្ពោះទៅរកសេចក្តីសុខ សុភមង្គល
- ប្រទេសជាតិ មានសុខសន្តិភាព មានការអភិវឌ្ឍរីកចម្រើនគ្រប់ផ្នែក។

## ខ.អំណះអំណាងក្នុងអក្សរសិល្ប៍

- រឿងកុលាបប៉ៃលិន៖ អ្នកនិពន្ធ ញ៉ុក ថែម បានលើកយកមកបង្ហាញឱ្យឃើញពីសកម្មភាពរបស់ចៅចិត្រដែលបានព្យាយាម តស៊ូសិក្សារៀនសូត្ររហូតបានទទួលចំណេះដឹងខ្ពង់ខ្ពស់, បានព្យាយាមប្រព្រឹត្តទង្វើល្អ តាមរយៈផ្លូវកាយ វាចា និងចិត្ត គួបផ្សំនឹងមានចិត្តភក្តីភាពជាមួយចៅហ្វាយនាយរបស់ខ្លួន ជាហេតុធ្វើឱ្យ លោកហ្លួងរតនៈសម្បត្តិពេញចិត្ត បានលើយកចៅចិត្រធ្វើជាកូនប្រសារ របស់លោក ជាហេតុធ្វើឱ្យចៅចិត្រទទួលបានសុភមង្គលនៅក្នុងជីវិត។
- រឿងទុំទាវ៖ អ្នកនិពន្ធភិក្ខុសោម បានរៀបរាប់ឱ្យឃើញពីសកម្មភាពរបស់នេនទុំ នេនពេជ្រដែលបានព្យាយាមសិក្សារៀនសូត្រ តាមរយៈផ្លូវធម៌ ផ្លូវលោក រៀនមុខវិជ្ជាជីវៈ ចេញធ្វើតោកចេះផ្លុំប៉ី ចេះស្មូតយ៉ាងពីរោះចោះសំឡេងល្បី គ្រប់ទិសទី ឮដល់ស្តេចរាមាជើងព្រៃ ក៏បានប្រទានងារជាម៉ឺនឯកថែមទៀត។
- រឿងរាមកេរ្តិ៍៖ អ្នកនិពន្ធបានបកស្រាយឱ្យឃើញពីសកម្មភាពរបស់ព្រះរាមដែលបានព្យាយាម ធ្វើការដោះស្រាយទំនាស់វិបត្តិដែលបានកើតមានឡើងរវាងពាក្យសត្យ និងប្រពៃណីព្រះមហាក្សត្រ ។ ជាដំណោះស្រាយព្រះរាមបានចាកចេញពីព្រះនគរ ធ្វើដំណើរចូលទៅក្នុងព្រៃបួសជាឥសីរយៈពេល១៤ឆ្នាំ ដើម្បីកុំឱ្យរាជវង្សមានទំនាស់ដោយសារតែខ្លួនជាអ្នកដឹកនាំមិនល្អ។

*«សិស្សអាចលើករឿងអ្វីមកបញ្ជាក់ក៏បានឱ្យមានលក្ខណៈត្រឹមត្រូវសមស្រប។ ចាប់ពីបីរឿងឡើងទៅត្រឹមត្រូវ គឺត្រូវបានពិន្ទុពេញ។» រឿងដែលអាចលើកយកមកបញ្ជាក់មានច្រើនដូចជាៈ រឿងចចក រឿងកុមារកំព្រា រឿងភូមិតិរច្ឆាន រឿងគូលីកំណែន រឿងព្រះអាទិត្យថ្មីរះលើផែនដីចាស់ តរឿងព្រះវេស្សន្តរ រឿងតេជោយ៉ត....*

- **សរុបមតិ**សរុបសេចក្ដីមកស្របទៅតាមការបកស្រាយនិងឧទាហរណ៍ដូចដែលបានបញ្ជាក់យ៉ាងច្បាស់ខាងលើ យើងអាចដឹងបានថាសេចក្ដីព្យាយាមគង់បានសម្រេចពិតប្រាកដមែន។

## ៣.បញ្ចប់សេចក្តី

- **វាយតម្លៃប្រធានៈ** ឆ្លងទៅតាមការអត្ថាធិប្បាយស្រាយបំភ្លឺខាងលើ យើងអាចសន្និដ្ឋានបានថា ពាក្យពេចន៍របស់បុព្វបុរសខាងលើពិតជាមានតម្លៃ មានអត្ថន័យដ៏ល្អ ជ្រាលជ្រៅបំផុតហើយថែមទាំងបានផ្ដល់ជាគតិអប់រំដល់យើងជាកូនចៅ ជំនាន់ក្រោយឱ្យខិតខំតស៊ូព្យាយាមពុះពារគ្រប់ឧបសគ្គទាំងអស់នោះយើងនឹងទទួលបាននូវសេចក្ដីសម្រេចទៅតាមបំណងប្រាថ្នារបស់យើងជាពុំខាន
- **ទស្សនៈផ្ទាល់ខ្លួនៈ** ដូច្នេះ ក្នុងនាមយើងជាកូនចៅជំនាន់ក្រោយ ក្រោយពីបានទទួលនូវបទពិសោធន៍អប់រំដ៏ល្អ។ ពីបុព្វបុរសយើង នោះយើងនឹងទទួលបានជោគជ័យជម្នះជាពុំខាន។

របទាបថ

# ប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ

## សម័យប្រឡង៖ ២០ សីហា ២០១៨

## វិញ្ញាសា៖ អក្សរសាស្ត្រខ្មែរ ( ថ្នាក់វិទ្យាសាស្ត្រសង្គម )

## រយៈពេល៖ ១៥០នាទី  ពិន្ទុ ១២៥

ប្រធាន មានទស្សនៈមួយថែងថា

« វិជ្ជាជាអលង្ការរបស់មនុស្សគ្រប់រូប » ។

ចូរអ្នកធ្វើការបកស្រាយដោយលើកឧទាហរណ៍ក្នុងអក្សរសិល្ប៍ខ្មែរមកបញ្ជាក់ ។

## អត្ថាធិប្បាយ

### ១.ផ្ដើមសេចក្ដី

- **លំនាំសេចក្ដី៖** នៅលើដែនពសុធាយើងនេះ វត្ថុមានតម្លៃមានច្រើនអនេកប្បការ ប៉ុន្តែមនុស្សវិញ មនុស្សគ្រប់រូបមានតម្លៃទៅបាន អាស្រ័យដោយមនុស្សនោះប្រកបទៅដោយគុណធម៌ ចំណេះដឹង ចំណេះធ្វើ សីលធម៌ និងបេះយោគយល់អធ្យាស្រ័យឱ្យគ្នាទៅវិញទៅមក។ចំណុចទាំងនេះជាគ្រឿងលម្អយិតយោងមនុស្សឱ្យមានតម្លៃឡើង។មិនមានព្រោះតែទ្រព្យសម្បត្តិ មាសពេជ្រកែវកង់ពិទូរ្យសូរកាន្ត ធ្វើឱ្យមនុស្សមានតម្លៃនោះទេ តែគឺព្រោះវិជ្ជា។
- **ចំណូលសេចក្ដី៖** ហេតុនេះហើយទើបមានទស្សនៈមួយថែងថា«វិជ្ជាជាអលង្ការរបស់មនុស្សគ្រប់រូប»
- **ចំណោទសេចក្ដី៖** តើទស្សនៈប្រធានដែលបានលើកឡើងខាងលើមានអត្ថន័យដូចម្ដេចខ្លះ?

### ២.តួសេចក្ដី

- **ឃ្លាគន្លឹះ៖** ដើម្បីបានជាមូលដ្ឋានក្នុងការបកស្រាយសម្រាយសេចក្ដីទស្សនៈប្រធានខាងលើយើងចាំបាច់ត្រូវយល់ពីពាក្យគន្លឹះប្រធានជាមុនសិន។
- **ពន្យល់ពាក្យ**
  - វិជ្ជា៖ ចំណេះដឹង ចំណេះប្រាជ្ញា សេចក្ដីដឹងច្បាស់ ការចេះទៅលើចំណេះជំនាញផ្សេងៗ។
  - អលង្ការ៖ ជាទ្រព្យសម្បត្តិដែលជាគ្រឿងលម្អមាន មាស ប្រាក់ កែវកង (ចិញ្ចៀន ខ្សែក ខ្សែដៃ) បើតាមន័យបង្កប់អលង្ការសំដៅលើបុគ្គលិកលក្ខណៈល្អរបស់មនុស្ស...។
- **ពន្យល់ន័យប្រធាន៖**

ទស្សនៈប្រធានមានន័យថា ចំណេះដឹង ចំណេះប្រាជ្ញា ការចេះដឹង ឬចំណេះជំនាញ ផ្សេងៗជាទ្រព្យសម្បត្តិរបស់មនុស្សគ្រប់រូប។

- **បកស្រាយប្រធាន៖**

**ក.បំភ្លឺន័យទូទៅ**

ជាការពិតណាស់ ចំណេះដឹងគឺជាទ្រព្យសម្បត្តិរបស់មនុស្សគ្រប់រូបទុកដូចជាគ្រឿងលម្អខ្លួនរបស់មនុស្ស ឱ្យមានតម្លៃ មានសេចក្ដីថ្លៃថ្នូរ។ កាលណាមនុស្សមានចំណេះវិជ្ជាធ្វើឱ្យមនុស្សជួបសេចក្ដីសុខមានជីវភាពធូរធារ មានសេចក្ដីថ្លៃថ្នូរ កិត្តិយស កេរ្តិ៍ឈ្មោះ លុយកាក់ទ្រព្យសម្បត្តិ។

**ខ.បំភ្លឺគំនិតសំខាន់របស់ប្រធាន**

ចំណេះវិជ្ជាជាទ្រព្យជាប់នឹងប្រាណ ចោរលួចមិនបាន ចាយច្រើនចម្រើនឡើង ភ្លើងមិនឆេះ កណ្ដុរមិនកាត់។ នៅក្នុងសង្គមរាល់រូបបុគ្គលដែលមានវិជ្ជា តែងបានអប់រំខ្លួនឱ្យក្លាយជាមនុស្សមានសីលធម៌ មានសុជីវធម៌ សប្បុរសធម៌ ហើយត្រូវបានគេលើកតម្លៃ ផ្ដល់កិត្តិយស ...អ្នកមានវិជ្ជាគឺមានជីវភាពធូធារ មានការងារសុចរិត។

**ឧទាហរណ៍ក្នុងអក្សរសិល្ប៍**

  - អក្សរសិល្ប៍ប្រជាប្រិយ

- **រឿងកុមារកំព្រា៖** តួអង្គកុមារប្អូន ដោយសារមានចំណេះធ្វើដុច ទើបទទួលបានលាភសក្ការៈ និងទទួលបានកិត្តិយសជាស្តេច។
- **រឿងមាយើង៖** ប្រពន្ធទី២ ដែលប្តូរពីនាយសំពៅមកមានប្រាជ្ញាឈ្លាវៃ អាចជួយមាណពមាយើង ឱ្យមានទ្រព្យសម្បត្តិ និងមានមុខមាត់ក្នុងសង្គម។
- **រឿងធនញ្ជ័យ៖** ធនញ្ជ័យមានភាពឆ្លាតវៃ អាចដោះសករាយបញ្ហាចំពោះមុខបានយ៉ាងល្អ។

○ អក្សរសិល្ប៍បុរាណ

- **រឿងរាមកេរ្តិ៍៖** ព្រះរាមរៀនចប់គម្ពីរត្រៃវេទ អាចលើកធ្នូស (កៅទណ្ឌសហសថាម) រួចឈ្នះអស់សត្រូវគ្រប់ទិសទី...
- **រឿងព្រះវេស្សន្តរ៖** ព្រះវេស្សន្តរក្រោយរៀនចប់សប់គ្រប់ត្រូវបានបិតាព្រះបាទស្រីសញ្ជ័យ អភិសេកឱ្យឡើងសោយរាជ្យ

○ អក្សរសិល្ប៍ទំនើប

- **រឿងទុំទាវ៖** ទុំមានចំណេះដឹងខាងវិជ្ជាស្មូតេះ រហូតល្បីល្បាញក្លាយជាម៉ឺនឯកប្រចាំវាំង...
- **រឿងតេជោយ៉ត៖** តួអង្គយ៉ត ដោយសារមានចំណេះវិជ្ជា ទើបក្លាយជាមេទ័ពនៅកំពង់ស្វាយ ហើយក៏ដោយសារភាពឈ្លាសវៃទើបជំទាវស្រែនព្រមរៀបការជាមួយដែរ។
- **រឿងកុលាបប៉ៃលិន៖** ដោយសារតែមានចំណេះវិជ្ជាទើបចៅចិត្រ ទទួលការទុកចិត្តពីលោកហ្លួងរតនសម្បត្តិ ហើយទទួលបាននាងឃុននារីជាភរិយា...។

- **រឿងព្រះអាទិត្យថ្មីរះលើផែនដីចាស់៖** លោករដ្ឋមន្ត្រីវ័យក្មេង បានទៅរៀននៅប្រទេសបារាំង ទើបមានចំណេះដឹងបម្រើការងាររហូតទទួលងារជារដ្ឋមន្ត្រី...។

- **សរុបមតិ** សរុបសេចក្ដីមក វិជ្ជាពិតជាទ្រព្យសម្បត្តិរបស់មនុស្សគ្រប់យ៉ាងប្រាកដមែន។

## ៣.បញ្ចប់សេចក្ដី

- **វាយតម្លៃប្រធាន៖** ឆ្លងទៅតាមការអធិប្បាយស្រាយបំភ្លឺខាងលើ យើងសន្និដ្ឋានបានថា មតិរបស់ប្រធានពិតជាមានអត្ថន័យ និងតម្លៃដ៏ល្អ ដែលអប់រំជនានុជនទូទៅឱ្យចេះស្គាល់តម្លៃនៃវិជ្ជា ព្រោះវិជ្ជាជាទ្រព្យ សម្បត្តិសំខាន់បំផុតសម្រាប់មនុស្សគ្រប់រូប។
- **ទស្សនៈផ្ទាល់ខ្លួន៖** ដូចនេះ ក្នុងនាមយើងជាអ្នកសិក្សាគប្បីប្រឹងប្រែងពង្រឹងសមត្ថភាពខ្លួនឯងគ្រប់ពេលវេលា ដើម្បីជាប្រយោជន៍ជួយដល់ខ្លួនឯង គ្រួសារ និងសង្គមជាតិឱ្យរីកចម្រើន ព្រោះធនធានមនុស្សដែលមានចំណេះដឹងជាមូលដ្ឋានចម្បងក្នុងការអភិវឌ្ឍប្រទេសជាតិ។

របទាបថ

# ប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ

## សម័យប្រឡង៖ ១៩ សីហា ២០១៩

## វិញ្ញាសា៖ អក្សរសាស្ត្រខ្មែរ (ថ្នាក់វិទ្យាសាស្ត្រពិត)

## រយៈពេល៖ ៩០នាទី ពិន្ទុ ៧៥

ប្រធាន « អក្សរសិល្ប៍ឆ្លុះបញ្ចាំងពីការប្រយុទ្ធរវាងភាវៈល្អ និងភាវៈអាក្រក់ »។ ចូរអ្នកបកស្រាយ ដោយយកអត្ថបទអក្សរសិល្ប៍មកបញ្ជាក់។

## អត្ថាធិប្បាយ

### ១.ផ្តើមសេចក្តី

- **លំនាំសេចក្តី ៖** និយាយទាក់ទងនឹងអក្សរសិល្ប៍
- **ចំណូលសេចក្តី៖** លើកយកបញ្ហាប្រធានមកសរសេរ
- **ចំណោទសេចក្តី៖** ចោទសួរលើប្រធានបទ (សួរបែបប្រធានពន្យល់)

### ២.តួសេចក្តី

- **ឃ្លាភ្ជាប់សេចក្តី**
- **ពន្យល់ពាក្យ**
  - ***អក្សរសិល្ប៍៖*** កម្រងអត្ថបទដែលលើកយកបញ្ហាមនុស្សមកចោទ និងដោះស្រាយទៅតាមសិល្បវិធីរបស់អ្នកនិពន្ធ។
  - ***ប្រយុទ្ធ៖*** តតាំង ប្រឆាំង ជម្លោះ ចម្បាំង...
  - ***ភាវៈល្អ៖*** ទង្វើ ឬសកម្មភាពដែលទ្រទ្រង់ភាពល្អប្រសើរ
  - ***ភាវៈអាក្រក់៖*** ទង្វើ ឬសកម្មាពដែលទ្រទ្រង់ភាពអាក្រក់។
- **ពន្យល់ន័យប្រធាន៖**

ទស្សនៈប្រធានមានន័យថា អត្ថបទរឿងទាំងឡាយសុទ្ធតែបានឆ្លុះបញ្ចាំងអំពីសកម្មភាព ឬទង្វើល្អ និងសកម្មភាពអាក្រក់ ឬទង្វើអាក្រក់របស់តួអង្គតំណាងមនុស្សក្នុងសង្គម។

- **បកស្រាយប្រធាន៖**
  - គំនិតទូទៅនៃអក្សរសិល្ប៍...
  - មូលហេតុនៃជម្លោះបណ្តាលមកពី៖
    - អំណាច
    - លាភសក្ការៈ
    - ស្នេហា
    - ប្រណែនឈ្នានីស
    - សង្គ្រាមឈ្លានពាន
    - ផលប្រយោជន៍បុគ្គល
    - យុត្តិធម៌ និងអយុត្តិធម៌
    - ជំនឿ ទំនៀមទម្លាប់ ប្រពៃណី ផ្នត់គំនិត ទស្សនៈ

  ឧទាហរណ៍
    - រឿងទុំទាវ៖ ម្តាយទាវ និងទាវ, ទុំទាវ និងអរជូន
    - រឿងរាមកេរ្តិ៍៖ ព្រះរាម និងក្រុងរាពណ៍...
    - រឿងកុលាបប៉ៃលិន៖ ហ្លួងរតនៈសម្បត្តិ និងបាឡាត់
    - រឿងធនញ្ជ័យ៖ ធនញ្ជ័យ និងសេដ្ឋី ធញ្ជ័យនិងព្រះរាជាខ្មែរ, ធនញ្ជ័យ និងស្តេចចិន...។

- **សរុបមតិ** សរុបសេចក្តីមក ឃើញថា គ្រប់អក្សរសិល្ប៍ទាំងអស់ដែលបានបកស្រាយបង្ហាញខាងលើសុទ្ធតែបញ្ជាក់ឱ្យឃើញពីទំនាស់ តតាំងរវាងទង្វើឬសកម្មភាពល្អ និងទង្វើ ឬសកម្មភាពអាក្រក់ ដោយសារអំណាច ស្នេហា ការប្រណែន ឈ្នានីស ផលប្រយោជន៍មិនយោគយល់អធ្យាស្រ័យឱ្យគ្នានិងគ្នា។

## ៣.បញ្ចប់សេចក្ដី

- **វាយតម្លៃប្រធានៈ** ឆ្លងតាមការបកស្រាយ និងលើឧទាហរណ៍ដូចបានបញ្ជាក់រួចមក យើងអាចវាយតម្លៃប្រធានខាងលើពិតជាមានអត្ថន័យ ខ្លឹមសារជ្រាលជ្រៅ និងសម្រាប់អប់រំយើងឱ្យសិក្សាស្រាវជ្រាវពីស្នាដៃអក្សរសិល្ប៍ ដែលអ្នកនិពន្ធចង់បង្ហាញទៅតាមសម័យកាលនីមួយៗ ។ ពិសេសឱ្យស្គាល់ ពីជំពូកមនុស្សបានច្បាស់លាស់ មុននឹងសេពគប់ ឬធ្វើការទំនាក់ទំនងគ្នា។
- **ទស្សនៈផ្ទាល់ខ្លួនៈ** ដូច្នេះ ក្នុងនាមយើងជាសិស្សត្រូវខិតខំសិក្សាគ្រប់ស្នាដៃអក្សរសិល្ប៍ ដើម្បីឱ្យមានគំនិតទូលំទូលាយទៅលើស្ថានភាពសង្គម និងស្រង់យកបទពិសោធន៍សម្រាប់ការរស់នៅប្រចាំថ្ងៃ និងរួមចំណែកអភិវឌ្ឍសង្គម។

រចនាបថ

# ប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ

## សម័យប្រឡង៖ ១៩ សីហា ២០១៩

## វិញ្ញាសា៖ អក្សរសាស្ត្រខ្មែរ (ថ្នាក់វិទ្យាសាស្ត្រសង្គម)

## រយៈពេល៖ ១៥០នាទី ពិន្ទុ ១២៥

ប្រធាន « អក្សរសិល្ប៍ខេមរនិយមបង្ហាញពីសង្គមខ្មែរតាមសម័យកាលនីមួយៗ »។ ចូរអ្នកធ្វើការបកស្រាយដោយយកអត្ថបទអក្សរសិល្ប៍ចំនួនបីមកបញ្ជាក់។

## អត្ថាធិប្បាយ

### ១.ផ្តើមសេចក្តី

- **លំនាំសេចក្តី៖** និយាយទាក់ទងនឹងអក្សរសិល្ប៍ខេមរនិយម និងការបង្ហាញសម័យកាលសង្គមនីមួយៗ ដែលអក្សរសិល្ប៍បង្ហាញ។
- **ចំណូលសេចក្តី៖** លើកយកបញ្ហាប្រធានមកសរសេរ
- **ចំណោទសេចក្តី៖** ចោទសួរលើប្រធានបទ( សួរបែបប្រធានពន្យល់)
    - តើប្រធានខាងលើមានខ្លឹមសារដូចម្តេចខ្លះ?
    - តើអក្សរសិល្ប៍ខេមរនិយមបង្ហាញពីសង្គមខ្មែរតាមសម័យកាលនីមួយៗយ៉ាងដូចម្តេចខ្លះ?

### ២.តួសេចក្តី

- **ឃ្លាភ្ជាប់សេចក្តី**
- **ពន្យល់ពាក្យ**

- ○ អក្សរសិល្ប៍ខេមរនិយមៈ ជាស្នាដៃអក្សរសិល្ប៍ទាំងឡាយណាដែលលើយកនូវតថភាពប្រពៃណី ទំនៀមទម្លាប់ ផ្នត់គំនិតរបស់ខ្មែរមកបង្ហាញទៅតាមសម័យកាលនីមួយៗ។
- ○ សម័យកាលៈ មានន័យថាកាលកំណត់នៃរបបគ្រប់គ្រងណាមួយរជ្ជកាល ឬពេលវេលាណាមួយ។

- **ពន្យល់ន័យប្រធានៈ**

ដូច្នេះ ប្រធានមានន័យថា អក្សរសិល្ប៍ខេមរនិយមបង្ហាញពីរបបគ្រប់គ្រងរជ្ជកាលបែបណាមួយរបស់សង្គមខ្មែរនីមួយៗ។

- **បកស្រាយប្រធានៈ**

បង្ហាញគំនិតៈ អក្សរសិល្ប៍ខេមរនិយម បង្ហាញពីសង្គមខ្មែរ តាមសម័យកាលនីមួយៗ ដូចជាៈ

- របបគ្រប់គ្រង ឬសម័យកាលប្រវត្តិសាស្ត្រ
- ជំនឿ
- សាសនា
- ទំនៀមទម្លាប់
- ប្រពៃណី
- ផ្នត់គំនិត
- ជីវភាព
- មុខរបរ
- សេដ្ឋកិច្ច នយោបាយ ។ល។

លើកឧទាហរណ៍ក្នុងស្នាដៃអក្សរសិល្ប៍

- ○ រឿងទុំទាវ
  - របបគ្រប់គ្រងៈ រាជានិយម
  - សម័យកាលៈ លង្វែក

- រជ្ជកាលៈ ព្រះបាទរាមាជើងព្រៃ
- ជំនឿៈ ការបន់ស្រន់ ការទស្សន៍ទាយ ការដាក់មន្តស្នេហ៍
- សាសនាៈ ព្រះពុទ្ធសាសនា និងព្រាហ្មណ៍សាសនា
- ទំនៀមទម្លាប់ៈ កូនប្រុសបួសរៀន ឯកូនស្រីចូលម្លប់
- ប្រពៃណីៈ ចែចូវ ស្ដីដណ្ដឹង រៀបការ
- ផ្នត់គំនិតៈ ទំ មិនធំជាងនាឡិ

○ រឿងគូលីកំណែន

- របបគ្រប់គ្រងៈ រាជានិយម
- សម័យកាលៈ អាណានិគមបារាំង ជប៉ុន និងការជ្រៀតជ្រែកពីសហរដ្ឋអាមេរិក
- ជំនឿៈ ការបន់ស្រន់ (ឧ. តាម៉ែត យាយម៉ុក នាងហោងបន់) ជឿលើកម្មផល (ឧ. សម្ដីយាយម៉ុក និងអាចារ្យឆេង)
- សាសនាៈ ព្រះពុទ្ធសាសនា (លឹមបួសរៀន)
- ទំនៀមទម្លាប់ៈ កូនប្រុសបួសរៀន កូនប្រុសត្រូវទៅបម្រើផ្ទះខាងស្រីមុនរៀបការ (ឧ.លឹមទៅបម្រើផ្ទះនាងហោងកាលចម្រូតអស់មួយខែ...)
- ប្រពៃណីៈ ចែចូវ ស្ដីដណ្ដឹង ជូនកំណាត់ (នៅជិតមួយខែរៀបការ)
- ជីវភាពរស់នៅៈ រាស្ត្រលំបាកលើបញ្ហាពន្ធដារ បញ្ហាកំណែនធ្វើផ្លូវថ្នល់ ធ្វើប្រលានយន្តហោះ។
- ផ្នត់គំនិតៈ ផ្ដល់សិទ្ធិសេរីភាព ឱ្យកូនក្នុងការជ្រើសរើសគូស្រករ សួរចិត្តកូនមុន នឹងសម្រេច។
- មុខរបរៈ ធ្វើស្រែ លក់ដូរ ។ល។

○ រឿងព្រះអាទិត្យថ្មីរះលើផែនដីចាស់

- របបគ្រប់គ្រង៖ រាជានិយម
- សម័យកាល៖ ចុងសម័យអាណានិគមបារាំង (ផែនដីចាស់) ដើមសម័យអាណានិគមបារាំង (ព្រះអាទិត្យថ្មី)
- វជ្ជកាល៖ ព្រះបាទនរោត្តមសីហនុ
- ជំនឿ៖ កម្មផល ភាពសុចរិតត្រឹមត្រូវ
- សាសនា៖ ព្រះពុទ្ធសាសនា
- ទំនៀមទម្លាប់៖ ធ្មប់បុរាណ ការធ្វើបុណ្យសព...
- ជីវភាពរស់នៅ៖ រាស្ត្រខ្មែរលំបាកដោយការរើសអើង អសន្តិសុខ ជិះជាន់ កេងប្រវ័ញ្ច អំពើអយុត្តិធម៌ ដែលជីវិតសមជួបក្នុងសម័យអាណានិគម និងភាពសុខដុមឥស្សរភាព សេរីភាព និងការយកចិត្តទុកដាក់លើកកម្ពស់ជីវភាពក្នុងរបបថ្មី...។
- មុខរបរ៖ កសិករ ធាក់ស៊ីក្លូ កម្មករ និងកសិករថ្មី (កសិករគំរូ) ក្នុងរបបថ្មី។...

*បញ្ជាក់៖បើសិស្សលើកផ្សេងពីឧទាហរណ៍ខាងលើឱ្យតែជាស្នាដៃអក្សរសិល្ប៍ខេមរនិយម ហើយមានការបកស្រាយរៀបរាប់ដូចខាងលើត្រូវផ្តល់ពិន្ទុពេញដូចគ្នា។ ឧទាហរណ៍ដូចជារឿង តេជោយ៉ត ថៅកែចិត្តចោរ ភូមិតិរច្ឆាន ផ្កាស្រពោន កុលាបប៉ៃលិន ។ល។*

- **សរុបមតិ៖** សរុបរួមមក អក្សរសិល្ប៍ខេមរនិយមពិតជាបានបង្ហាញពីសង្គមខ្មែរតាមសម័យកាលនីមួយៗមែន ព្រោះស្នាដៃទាំងអស់ បានបង្ហាញពីតថភាពក្នុងសម័យកាលនីមួយៗ តាមរយៈការលើកយកនូវរបបគ្រប់គ្រង ព្រឹត្តិការណ៍ វប្បធម៌ និងជីវភាពផ្សេងៗ មកលាតត្រដាងយ៉ាងជាក់ស្តែងដូចមានរឿងទាំងបីខាងលើជាឧទាហរណ៍ស្រាប់។

## ៣.បញ្ចប់សេចក្តី

- **វាយតម្លៃប្រធាន៖** មតិរបស់ប្រធានពិតជាមានអត្ថន័យ និងតម្លៃដ៏ល្អ ដោយបង្ហាញឱ្យយើងឃើញពីតួនាទី ឬមុខងារអក្សរសិល្ប៍ខេមរនិយមដែលបានឆ្លុះបញ្ចាំងពីសម័យកាលនីមួយៗ...។
- **ទស្សនៈផ្ទាល់ខ្លួន៖** ដូចនេះ ក្នុងនាមយើងជាអ្នកសិក្សា...។

របនាបថ

*បញ្ជាក់៖ ចាប់ពីឆ្នាំ ២០១៤មក វិញ្ញាសាអក្សរសាស្ត្រខ្មែរមានតែតែងសេចក្ដីមួយ*

## ឯកសារយោង


- សៀវភៅអត្រាកំណែរបស់ក្រសួងអប់រំ យុវជននិងកីឡា
- Google

ម៉ៅ ម៉ារ៉ាឌី - Mao Marady




(បទកាកគតិ)

ចង់ចេះចាំច្បាស់ ល្អិតល្អន់ល្អះ
ក្បូរក្បាច់ក្បោះក្បាយ ប្រឹងប្រែងប្រុងប្រៀប
ខិតខំខ្វល់ខ្វាយ គិតគូរគាស់កាយ
រើរើសរិះរក។

រិះរករស់រៀន ស្វះស្វែងព្យាយាម
ពន្លូតពន្លក ពង្រីកពង្រាយ
ល្អរក្សាយក ខុសខំខិតរក
ដំណោះដោះស្រាយ។

ចិត្តច្បាស់ចង់ចេះ លល្បួងលះលេស
ខ្ជេញខ្ជិលខ្ជាត់ខ្ជាយ កុំចាំថ្ងៃស្អែក
នោះនាំនឿយណាយ ក្រែងមិនសប្បាយ
រៀនកុំចាំស្អែក។

១៨ មេសា ២០២០
តែងដោយ៖ ម៉ៅ ម៉ារ៉ាឌី (ឫស្សីព្រៃ)